00238422

D99/3/24

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / NOV / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fuy

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| សំណុំរឿងក្ដីលេខ | : | 001/18-07-2007អ.វ.ត.ក/ក.ស.ច.ស.ស.(PTC 02) |
| ដាក់ជូន | : | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទរបស់ឯកសារ | : | ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ |
| ភាគីដាក់ជូនសារណា | : | *អ្នកជូនយោបល់តុលាការដែលមិនមែនជាភាគីនៃរឿងក្ដី* លោកសាស្ត្រាចារ្យ Antonio Cassese ជាអគ្គនិពន្ធនាយក ជាសមាជិកក្រុមប្រឹក្សា និងគណៈកម្មការនិពន្ធនាយក *ទស្សនាវដ្ដី យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (Journal of International Criminal Justice)* |
| ភាសាដើម | : | ភាសាអង់គ្លេស |
| ប្រភេទនៃឯកសារ | : | សាធារណៈ |

ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សារណាអំពីទ្រឹស្ដីសហឧក្រិដ្ឋកម្មរួម

## ដោយសាស្ត្រាចារ្យ ANTONIO CASSESE សមាជិក *ទស្សនាវដ្ដីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*

<u>ដាក់ជូនដោយ</u>:

**ម្ចាស់សារណាដែលមិនមែនជាភាគីនៃរឿងក្ដី:**

លោក Antonio CASSESE សាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Florence និងជាអគ្គនិពន្ធនាយក *ទស្សនាវដ្ដីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*

លោកស្រី Mary De Ming FAN ជំនួយការសាស្ត្រាចារ្យច្បាប់ មហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យ Washington និងជាសមាជិកគណៈកម្មការនិពន្ធនាយក នៃ *ទស្សនាវដ្ដីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*

លោក Salvatore ZAPPALA សាស្ត្រាចារ្យផ្នែកច្បាប់អន្តរជាតិ នៃមហាវិទ្យាល័យច្បាប់ សាកលវិទ្យាល័យ Catania ជាសមាជិកក្រុមប្រឹក្សានិពន្ធនាយក និងជាប្រធាននិពន្ធនាយកនៃ *ទស្សនាវដ្ដីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*

<u>ជូនចំពោះ</u>:

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង — លោក William SMITH
លោក Robert PETIT — លោក ពេជ្រ សម្បត្តិ
លោក យ៉េត ចរិយា — លោក Alex BATES

**ជនត្រូវចោទ:**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**សហមេធាវីការពារក្ដី:**

លោក ការ សាវុត្ថ — លោក Francois ROUX

**មេធាវីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក គង់ ពិសី — លោក គីម ម៉េងឃី
លោក ហុង គឹមសួន — លោក Martin JACQUIN
លោក យុង ផានិត — លោកស្រី ម៉ុច សុវណ្ណារី
លោកស្រី Silke STUDZINSKY

00238423

D99/3/24

សេចក្តីព្រាងសំណុំរឿងក្តីព្រហ្មទណ្ឌលេខ: 001/18-07-2007អ.វ.ត.ក/ក.ស.ច.ស (PTC 02)

## មាតិកា


**សេចក្តីផ្តើម និងចំណាប់អារម្មណ៍/លំនាំបញ្ហា** ........ 1

**សង្ខេបអង្គហេតុពាក់ព័ន្ធ** ........ 2

**សង្ខេបសាវតានីតិវិធីពាក់ព័ន្ធ** ........ 4

**សង្ខេបនៃការវិភាគ** ........ 6

**ការវិភាគ** ........ 8

I. **ភាពទូទៅនៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម: គោលការណ៍វិសាលភាព ព្រំដែន** ........ 8

**ក. ទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួមទាំង៣** ........ 8

**ខ. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ** ........ 14

II. **គោលការណ៍នៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម ដែលបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនអំឡុងឆ្នាំ១៩៧៥** ........ 16

**ក. ការវិវត្តន៍នៃបញ្ញត្តសហកម្មឧក្រិដ្ឋកម្មរួម** ........ 17

១. ទម្រង់ទី១ “ទម្រង់មូលដ្ឋាន” នៃសហកម្មឧក្រិដ្ឋកម្មរួម : ច្បាប់យុត្តិសាស្ត្រ ........ 21

២. ម្រង់ទី២ “ទម្រង់ជាប្រព័ន្ធ” នៃសហកម្មឧក្រិដ្ឋកម្មរួមទ: ច្បាប់យុត្តិសាស្ត្រ ........ 24

៣. ទម្រង់ទី៣ “ទម្រង់ទូលាយ” នៃសហកម្មឧក្រិដ្ឋកម្មរួម: ច្បាប់យុត្តិសាស្ត្រ ........ 25

**ខ. ឫសគល់គោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមក្នុងប្រព័ន្ធជាតិសំខាន់ៗ** ........ 31

III. **អង្គជំនុំជម្រះអាច និងគួរអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿងសមស្របនានា** ........ 33

**ក. ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមគឺស្របគ្នានឹងគោលការណ៍គ្មានច្បាប់គឺគ្មានទោស** ........ 34

**ខ. កង្វល់អំពីការទទួលខុសត្រូវទូលំទូលាយជ្រុលត្រូវបានការកាត់បន្ថយនៅកម្រិតអន្តរជាតិ និងដោយការយកចិត្តទុកដាក់អំពីផលប្រយោជន៍សំខាន់ៗ** ........ 39

**សេចក្តីសន្និដ្ឋាន** ........ 43

00238424

D99/3/24

សេចក្តីព្រាងសំណុំរឿងក្តីព្រហ្មទណ្ឌលេខ: 001/18-07-2007អ.វ.ត.ក/ក.ស.ច.ស (PTC 02)

## សេចក្តីផ្តើម និងចំណាប់អារម្មណ៍/លំនាំបញ្ហា

១. អង្គបុរេជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ Antonio Cassese ដែលជាអគ្គនិពន្ធនាយក និងសមាជិកផ្សេងៗទៀតក្រុមប្រឹក្សានិពន្ធនាយក និងគណៈកម្មការនិពន្ធនាយក របស់*ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* មកជាអ្នកជូនយោបល់តុលាការដែលមិនមែនជាភាគីនៃរឿងក្តី ដើម្បីវិភាគទៅលើទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម (តទៅនេះហៅថា “JCE”) ដែលជាប់ពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ទៅលើដីកាដំណោះស្រាយចំពោះសំណុំរឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” (តទៅនេះហៅថា “ឌុច”)[1]។

២. សហព្រះរាជអាជ្ញាសូមឲ្យកែតម្រូវដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចោទប្រកាន់ឌុច ពីបទឧក្រិដ្ឋតាមរយៈការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមមួយ[2]។ ទោះបីជាដីកាដំណោះស្រាយបានលើកឡើងថា ឌុចជាអ្នកគ្រប់គ្រងការឃុំខ្លួន ការសួរចម្លើយ និងកន្លែងធ្វើឃាត ដែលគេស្គាល់ថា មន្ទីរស-២១ ដោយរយៈបញ្ជារបស់ ឌុច ផ្ទាល់ ដែលតម្រូវឲ្យ ឌុច “ទទួលខុសត្រូវខ្ពស់បំផុតនៅមន្ទីរស-២១” ក៏ដោយ ក៏ដីកាបញ្ជូនសំណុំរឿងទៅជម្រះគ្រាន់តែបានចោទប្រកាន់ថា ឌុច ត្រូវទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តនូវរាល់អ្វីៗដែលកើតឡើងក្រោមការទទួលខុសត្រូវរបស់ខ្លួន ដូចជា “ការបានធ្វើទារុណកម្ម ឬធ្វើបាបដល់អ្នកជាប់ឃុំនៅមន្ទីរស-២១ តែប៉ុណ្ណោះ”[3]។

៣. អង្គបុរេជំនុំជម្រះបានស្នើសុំឲ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ផ្តល់ជាយោបល់អំពី:

(១) ការវិវត្តនៃទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម និងការវិវត្តរបស់និយមន័យនៃការទទួលខុសត្រូវក្នុងទម្រង់នេះ ដោយគិតក្នុងកំឡុងពេលជាក់លាក់ពីឆ្នាំ១៩៧៥-៧៩

(២) តើ JCE ក្នុងទម្រង់នៃការទទួលខុសត្រូវអាចអនុវត្តចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដែរឬទេ ដោយយោងទៅលើអង្គហេតុដែលថាបទឧក្រិដ្ឋទាំងនោះបានប្រព្រឹត្តឡើងនៅក្នុងកំឡុងពេលឆ្នាំ១៩៧៥-៧៩[4]។

---

1
2
3
4

៤. សាស្ត្រាចារ្យ Cassese គឺជាប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិនៅ Yugoslavia ("ICTY") មុនគេបង្អស់។ បច្ចុប្បន្ន គាត់ជាសាស្ត្រាចារ្យច្បាប់អន្តរជាតិ នៅសាកលវិទ្យាល័យ Florence និងជាអគ្គនិពន្ធនាយករបស់ *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*។

៥. *ទស្សនាវដ្តី* នេះ ត្រូវបានបោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព Oxford University Press ហើយត្រូវបានបង្កើតឡើងក្រោមស្នាដៃរបស់មេធាវី និងអ្នកស្រាវជ្រាវល្បីៗជាច្រើន ដើម្បីជម្រុញឱ្យមានការចងក្រងឯកសារផ្ទុះបញ្ចាំងជារួមទៅលើបញ្ហាប្រឈមនានាទាក់ទងនឹងច្បាប់អន្តរជាតិ។ *ទស្សនាវដ្តី* នេះគឺជាវេទិកា *មួយសម្រាប់ដោះស្រាយ និងវិភាគរាល់បញ្ហាធំៗនានាដែលកើតមាននៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ស្តីអំពី* គុណតម្លៃនៃច្បាប់ យុត្តិសាស្ត្រ វិទ្យាសាស្ត្រខាងបទឧក្រិដ្ឋ ទស្សនៈព្រហ្មទណ្ឌ និងសាវតារបស់ស្ថាប័នតុលាការអន្តរជាតិនានា។

៦. សមាជិកផ្សេងៗទៀតនៃក្រុមប្រឹក្សានិពន្ធនាយក ឬគណៈកម្មការនិពន្ធនាយក ដូចមានរាយនាមបន្តទៅនេះ ក៏បានចូលរួមជាអ្នកផ្តល់យោបល់តុលាការជាមួយនឹងសាស្រាចារ្យ Cassese ផងដែរ: សាស្ត្រាចារ្យ Mary De Ming Fan លោកស្រី Vanessa Thalmann និងសាស្ត្រាចារ្យ Salvatore Zappala។

## សង្ខេបអង្គហេតុពាក់ព័ន្ធ

៧. ជនត្រូវចោទ ឌុច ត្រូវបានចោទប្រកាន់ពីបទបានជួយធ្វើផែនការ និងដឹកនាំមន្ទីរឃុំឃាំង និងកន្លែងពិឃាត ស-២១ ដែលមន្ទីរនោះជាអគ្គបញ្ជាការរបស់ ប៉ូលីសសម្ងាត់ពិសេស (the Special Branch of the Secret Police) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[5]។

៨. មន្ទីរស-២១ បានចាប់ផ្តើមដំណើរពេញលេញក្នុង ខែតុលា ឆ្នាំ១៩៧៥ ដោយពេលដំបូងនោះ ឌុច បំពេញតួនាទីជាអនុប្រធានអង្គភាពសួរចម្លើយ[6]។ ឌុច បានក្លាយទៅជាប្រធាន និងលេខាមន្ទីរស-២១ ក្នុងខែមីនា ឆ្នាំ១៩៧៦[7]។ ទោះបីជា ឌុច បានចាត់តាំងឱ្យមានអនុប្រធានទទួលខុសត្រូវមើលដំណើរការប្រចាំថ្ងៃនៅក្នុងមន្ទីរក៏ដោយ ក៏គាត់ "បានសារភាពថាគាត់នៅតែបន្តពិនិត្យ

5

6

7

មើលការសួរចម្លើយដោយផ្ទាល់ ចំពោះអ្នកទោសទាំងឡាយណាដែលសំខាន់ និងដើម្បីបំពេញតួនាទីជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅមន្ទីរស-២១"[8]។

៩. គោលបំណងសំខាន់មួយនៃគោលបំណងជាចម្បងដែលនាំឲ្យមានការបង្កើតមន្ទីរស-២១នោះគឺការយកចម្លើយសារភាពដើម្បីស្វែងរកខ្សែរយៈ អ្នកដែលគេគិតថាជាជនក្បត់បន្តទៀត[9]។ ប្រជាជនមួយចំនួនធំ ដែលត្រូវគេសួរចម្លើយ ត្រូវបានគេធ្វើទារុណកម្មជាច្រើនលើកច្រើនសារ[10]។

១០. ជនដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ បានឲ្យដឹងថា គេមានបំណងយកអ្នកទោសមន្ទីរស-២១ ទាំងអស់ទៅសម្លាប់[11]។ ជនរងគ្រោះទាំងនោះ រួមមាន បុរស ស្ត្រី និងកុមារ[12]។ អ្នកទោសជាច្រើនត្រូវបានគេសម្លាប់ដោយចេតនា រីឯអ្នកទោសផ្សេងៗទៀត ត្រូវគេយកទៅវាយធ្វើបាបធ្វើទារុណកម្ម ដោយចារីនោះក៏បានដឹងផងដែរថា អំពើទារុណកម្មនោះ អាចធ្វើឲ្យមនុស្សស្លាប់[13]។ លើសនេះទៅទៀត ស្ថានភាពរស់នៅក្នុងមន្ទីរស-២១ "ត្រូវបានគេចាត់ទុកថាជាមូលហេតុអាចនាំមកនូវសេចក្តីស្លាប់ដល់ជនដែលជាប់ឃុំទាំងឡាយដែរ" ដូចជា តាមរយៈការមិនផ្តល់អាហារឲ្យបរិភោគ និងការថែទាំសុខភាពឲ្យមិនបានគ្រប់គ្រាន់ជាដើម[14]។

១១. មានជនជាប់ឃុំលើសពី ១២.៣៨០នាក់ បានស្លាប់[15]។ ការសម្លាប់ចុងក្រោយបានធ្វើឡើងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[16]។ កងទ័ពវៀតណាមបានចូលមកទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបាន ព្រមទាំងការដឹកនាំរបបនេះបាន ដួលរលំខ្ចាត់ខ្ចាយ។ កងទ័ពវៀតណាមទាំងនោះបានឃើញ មនុស្សដែលគេទើបនឹងសម្លាប់ថ្មីៗទាំងជើងជាប់ច្រវ៉ាក់នឹងគ្រែដែក នៅមន្ទីរស-២១[17]។

8
9
10
11
12
13
14
15
16
17

00238427

D99/3/24



**សង្ខេបសាវតានីតិវិធីពាក់ព័ន្ធ**

១២. ក្នុងឆ្នាំ១៩៩៩ គេបានដឹងថា ឌុច នៅមានជីវិតរស់ដោយប្រើប្រាស់ឈ្មោះមួយផ្សេងទៀត ហើយក៏ត្រូវចាប់ខ្លួនដោយអាជ្ញាធរយោធាកម្ពុជា[18]។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលទើបតែបង្កើតថ្មីនាពេលនោះ បានចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដោយមានបញ្ជាក់ពីបទចោទប្រកាន់ទៅលើ ឌុច និងបុគ្គលបួនរូបផ្សេងទៀត[19]។ ក្នុងអំឡុងពេលនៃការស៊ើបអង្កេត ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៤៩[20]។ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់បំបែកសំណុំរឿងក្តីរបស់ ឌុច ដែលពាក់ព័ន្ធនឹងមន្ទីរស-២១ ដាច់ដោយឡែក ដើម្បីជម្រុញចំណាត់ការដំណោះស្រាយឱ្យបានលឿន[21]។

១៣. នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានដាក់ចេញនូវដីកាដំណោះស្រាយដោយចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរទៅលើ អនុសញ្ញាទីក្រុងហ្សឺណែវ[22]។ ដីកាដំណោះស្រាយ បានលើកឡើងពីសកម្មភាពជាក់លាក់នានា ដែលមានបញ្ជាក់នៅក្នុងការស៊ើបអង្កេតតុលាការ ដូចជាការបង្កឱ្យមានមនុស្សឃាត និងធ្វើទារុណកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ប៉ុន្តែដីកាបានសម្រេចថា "សកម្មភាពទាំងនេះ បានប្រព្រឹត្តឡើងក្រោមការបែងចែកក្នុងទ្រង់ទ្រាយកម្រិតខ្ពស់ដែលមានតាមផ្លូវច្បាប់" ដោយបានបន្តអនុវត្តទៅជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[23]។ ដីកាដំណោះស្រាយបានដាក់ចេញនូវទម្រង់នៃការទទួលខុសត្រូវចំនួន ៦ គឺ: ការប្រព្រឹត្តិ ការចេញបញ្ជា ការទទួលខុសត្រូវចំពោះការចេញបញ្ជា ការរៀបចំផែនការ ការញុះញង់ និងជ្រោមជ្រែងឱ្យប្រព្រឹត្តបទល្មើស[24]។ ចំពោះការទទួលខុសត្រូវក្រោមទម្រង់នៃ

18
19
20
21
22
23
24

ការប្រព្រឹត្ត ដីកាដំណោះស្រាយគ្រាន់តែចោទប្រកាន់ទៅលើការទទួលខុសត្រូវរបស់ ឌុច "ដោយផ្ទាល់ចំពោះការធ្វើទារុណកម្ម ឬធ្វើបាបអ្នកជាប់ឃុំនៅមន្ទីរស-២១ តែប៉ុណ្ណោះ"[25]។

១៤. នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយ[26]។ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយប្រឆាំងចំពោះ: (១) សេចក្តីសម្រេចមិនចោទប្រកាន់ ឌុច ពីបទមនុស្សឃាត និងធ្វើទារុណកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និង(២) ការលុបចោល JCE ជាទម្រង់នៃការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលបានចោទប្រកាន់នានា[27]។

១៥. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ Cassese ក្នុងឋានៈគាត់ជាអគ្គនិពន្ធនាយក នៃ *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* និងសមាជិកក្រុមប្រឹក្សា និងសមាជិកនៃគណៈកម្មការនិពន្ធនាយក នៃ *ទស្សនាវដ្តី* ឱ្យដាក់សារណាស្តីអំពីការបង្កើត និងការវិវត្តនៃទ្រឹស្តី JCE ហើយថា តើទម្រង់នៃការទទួលខុសត្រូវនេះ អាចយកមកអនុវត្តនៅក្នុង អ.វ.ត.ក ដើម្បីវិនិច្ឆ័យបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់១៩៧៩ បានដែរឬក៏មិនបាន[28]។ អង្គបុរេជំនុំជម្រះក៏បានធ្វើលិខិតសុំយោបល់ដូចគ្នានេះដែរ ទៅសាស្ត្រាចារ្យ Kai Ambos និងសាកលវិទ្យាល័យ McGill University[29]។

១៦. នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨ អៀង សារី ដែលជាជនត្រូវចោទនៅក្នុងរឿងក្តីមួយផ្សេងទៀតនោះ បានដាក់បណ្តឹងជិតចិត្តដល់សាស្ត្រាចារ្យ Cassese និងសមាជិកនិពន្ធនាយកផ្សេងៗទៀត មិនឱ្យដាក់សារណារបស់ពួកគេ[30]។ អៀង សារី បានអះអាងថា សារណារបស់អ្នកដែលមិនមែនជាភាគីរឿងក្តី អាចនឹង "ដឹងលទ្ធផលជាមុនរួចទៅហើយ [sic]" ដោយសារសាស្ត្រាចារ្យ Cassese បានបំពេញតួនាទីក្នុងអង្គចៅក្រមសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត Yugoslavia (ICTY) និងជាអ្នកបានដាក់ចេញនូវសេចក្តីសម្រេចនៅក្នុងរឿងក្តីរវាង*ព្រះរាជអាជ្ញា និង Tadic*[31] ដែលបានបញ្ជាក់ JCE ថាជាទម្រង់នៃការទទួលខុសត្រូវមួយ[32]។

25
26
27
28
29
30
31
32

១៧. មុនពេលដែលអង្គបុរេជំនុំជម្រះ ផ្ញើលិខិតអញ្ជើញរបស់ខ្លួនទៅជូនអ្នកផ្តល់យោបល់ដែលមិនមែនជាភាគីនៃរឿងក្តី អៀង សារីបានដាក់នូវសំណើមួយ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ដើម្បីលើកឡើងទឡ្ហីករណ៍នានាស្តីពីការទទួលខុសត្រូវតាមទម្រង់ JCE នៅក្នុងសំណុំរឿងក្តីរបស់ ឌុច[33]។ នៅថ្ងៃទី៦ ខែតុលាឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានច្រានចោលសំណើរបស់ អៀង សារី ដោយបញ្ជាក់ថាសេចក្តីសម្រេចនៅក្នុងរឿងក្តីរបស់ ឌុច នឹងមិនយកមកអនុវត្តដោយផ្ទាល់ ក្នុងរឿងក្តី អៀង សារី ទេ ហើយជនត្រូវចោទដទៃទៀតមិនមានសិទ្ធិចូលពាក់ព័ន្ធ នៅក្នុងរឿងក្តីដែលពួកគេមិនមែនជាភាគីដែរ[34]។

១៨. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានច្រានចោលបណ្តឹងអៀង សារី ដែលទាមទារឱ្យមានការដកសិទ្ធិជាអ្នកផ្តល់យោបល់តុលាការពីសាស្ត្រាចារ្យ Cassese និងសមាជិកនិពន្ធនាយកដទៀតនៃ *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ*[35]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អៀង សារី មិនមែនជាភាគីនៅក្នុងរឿងក្តីរបស់ ឌុចទេ ដូច្នេះ "សិទ្ធិក្នុងការប្តឹងផ្តល់" អំពីបញ្ហាបណ្តឹងជិតចិត្តនោះទេ ដូចបានបង្ហាញរួចមកហើយ តាមរយៈការច្រានចោលរបស់អង្គបុរេជំនុំជម្រះចំពោះបណ្តឹងរបស់ អៀង សារី ដែលស្នើសុំចូលពាក់ព័ន្ធ និងដាក់សារណាស្តីពីការទទួលខុសត្រូវតាមទម្រង់ JCE។ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានច្រានចោលបណ្តឹងជិតចិត្តរបស់ អៀង សារី ដោយសារតែគាត់គ្មានសិទ្ធិធ្វើបណ្តឹងនេះឡើយ[36]។

១៩. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចថានឹងចេញសេចក្តីសម្រេចស្តីអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដោយលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[37]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្តីពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ទៅលើដីកាដំណោះស្រាយនឹងត្រូវប្រកាសនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨[38]។

**សង្ខេបនៃការវិភាគ**

33
34
35
36
37
38

២០. JCE មិនមែនជាបទឧក្រិដ្ឋទេ ប៉ុន្តែជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ទ្រឹស្តីនេះជាផ្នែកសំខាន់របស់ច្បាប់អន្តរជាតិ ដែលធានាថា បុគ្គលណាម្នាក់ក៏ដោយ ឲ្យតែបានប្រព្រឹត្តខុស មិនអាចបានលាក់បំពួននៅក្នុងស្រទាប់នៃឧក្រិដ្ឋភាពជារួមឡើយ ហើយក៏មិនអាចគេចវេសពីការទទួលខុសត្រូវនោះដែរ។ គោលការណ៍របស់ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយនោះ បានចែងយ៉ាងច្បាស់បន្ទាប់ពីសង្គ្រាមលោកលើកទី II និងបានដាក់ជាវិធានជាទំនៀមទម្លាប់ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅឆ្នាំ១៩៧៥។ ការវិភាគ និងការរៀបចំជាប្រព័ន្ធនៃបណ្តាសំណុំរឿងក្តី ដែលបានកើតឡើងក្នុងសង្គ្រាមលោកលើកទី II ប្រព្រឹត្តទៅដោយអនុវត្តតាមគោលការណ៍ធម្មនុញ្ញ របស់តុលាការយោធាអន្តរជាតិ និងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ (Control Council Law) លេខ១០ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ ដោយបានបង្ហាញពីទម្រង់ទាំង៣របស់ JCE ជាទម្រង់នៃការទទួលខុសត្រូវ: (១) ទម្រង់ "មូលដ្ឋាន" ជាទម្រង់ដែលអ្នកចូលរួមសកម្មភាពទាំងអស់ បានអនុវត្តសកម្មភាពទៅតាមការរៀបចំរួមគ្នា និងប្រកាន់ខ្ជាប់នូវឆន្ទៈក្នុងការប្រព្រឹត្តិបទល្មើសដូចគ្នា ទោះបីជាអ្នកចូលរួមសកម្មភាពទាំងនោះ បំពេញតួនាទីខុសៗគ្នា និងចូលរួមចំណែកក្នុងកម្រិតខុសៗគ្នាក៏ដោយ។ (២) ទម្រង់ "ជាប្រព័ន្ធ" មានលក្ខណៈពិសេសខុសពីទម្រង់ទីមួយ ដោយមានការរៀបចំឲ្យមានជាជំរុំប្រមូលផ្តុំ និងមន្ទីរឃុំឃាំងជាដើម។ (៣) ទម្រង់ "ទូលាយ" ជាទម្រង់ដែលសំដៅលើការទទួលខុសត្រូវរបស់ចារីមួយផ្សេងទៀតបានប្រព្រឹត្តបទឧក្រិដ្ឋ ទោះបីជាបទឧក្រិដ្ឋនោះ មិនស្ថិតនៅក្នុងផែនការរួម ប៉ុន្តែការប្រព្រឹត្តិបទឧក្រិដ្ឋនោះ អាចផ្តល់ជាផលវិបាកអាចប្រមើលឃើញជាមុន និងតាមធម្មជាតិ ថាមានផលប៉ះពាល់ជួយឲ្យសម្រេចគោលបំណងធំជារួមបាន។

២១. ការទទួលខុសត្រូវចំពោះការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន ដោយគោលការណ៍នេះមានភាពស៊ីសង្វាក់ទៅនឹងគោលការណ៍ *ពុំមានបទល្មើសបើពុំមានច្បាប់ចែង* ដោយហេតុថា (១) ដូចអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ Yugoslavia បានបកស្រាយរួចមកហើយ ចរិតលក្ខណៈទំនៀមទម្លាប់ (customary character) នៃគោលការណ៍ទទួលខុសត្រូវតាមទម្រង់ JCE និងការធ្វើសេចក្តីសម្រេចដោយគ្មានការប្រែប្រួលជាបន្តបន្ទាប់ លិខិតុបករណ៍ និងច្បាប់ជាតិផ្សេងៗទៀតដែលមានចែងអំពីគោលការណ៍ JCE ត្រូវបានគេកត់សម្គាល់ដោយសមហេតុផល ហើយបានធ្វើឲ្យទម្រង់នៃការទទួលខុសត្រូវមួយនេះអាច ប្រមើលមើលទុកជាមុនបាន (២) ទោះជាស្ថិតក្នុងកម្រិតណាក៏ដោយ ច្បាប់ព្រហ្មទណ្ឌកម្ពុជា និងរួមទាំងច្បាប់បារាំងដែលក្រុម

ព្រហ្មទណ្ឌកម្ពុជាយកជាមូលដ្ឋាននោះ ត្រូវផ្តល់ការកត់សម្គាល់យ៉ាងគ្រប់គ្រាន់ អំពីការទទួលខុសត្រូវតាមទម្រង់ JCE។ ទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួម អាចអនុវត្តបាន តាមករណីសមស្របនៅអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាចំពោះការទទួលខុសត្រូវលើការប្រព្រឹត្តិបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងស្រុង ក្នុងករណីដែលតួនាទីជាក់លាក់របស់អ្នកចូលរួមសកម្មភាពនីមួយៗ ក្នុងគោលបំណងរួមនោះ អាចនឹងត្រូវបិទបាំងដោយវិសាលភាពធំធេង និងភាពស្មុគស្មាញរបស់បទឧក្រិដ្ឋនោះ។ ការទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវនេះនឹងធានាឲ្យមានភាពស៊ីសង្វាក់គ្នាចំពោះការអនុវត្តច្បាប់នៅក្នុងតុលាការក្នុនកាត់ និងអន្តរជាតិ ដែលធ្លាប់មានពិសោធន៍ អនុវត្តគោលការណ៍ការទទួលខុសត្រូវចំពោះការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួម ហើយនឹងកំពុងបន្តអនុវត្តទ្រឹស្តីនេះនាពេលបច្ចុប្បន្ន ក្នុងបរិបទផ្សេងៗគ្នា នៅអតីត Yugoslavia, Rwanda, Sierra Leone, East Timor និងប្រទេស Iraq[39]។

## ការវិភាគ

### I. ភាពទូទៅនៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម: គោលការណ៍ វិសាលភាព ព្រំដែន

២២. ផ្នែកនេះនឹងបកស្រាយទម្រង់ទាំង៣នៃការទទួលខុសត្រូវ និងសនិទានកម្ម វិសាលភាពនិងព្រំដែននៃសហកម្មឧក្រិដ្ឋកម្មរួម។ ចំពោះ២ផ្នែកបន្តទៅទៀត នឹងឆ្លើយតបនឹងសំនួរទាំងឡាយ ដែលបានដាក់ជូនអ្នកផ្តល់យោបល់ដែលមិនមែនជាភាគីនៃរឿងក្តី ដោយនឹងធ្វើការវិភាគអត្ថិភាពនៃវិធានទំនៀមទម្លាប់ នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ស្តីអំពី JCE មុនឆ្នាំ១៩៧៥ និងហេតុផលដែលទ្រឹស្តី JCE អាចអនុវត្ត ហើយនឹងគួរអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញ ចំពោះសំណុំរឿងក្តីដែលមានលក្ខណៈសមស្រប។

### ក. ទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួមទាំង៣

២៣. នៅក្នុងច្បាប់អន្តរជាតិ មានការទទួលខុសត្រូវតាមទម្រង់ JCE ចំនួន៣យ៉ាង[40]។ ទម្រង់ទី១ និងជាប្រភេទនៃការទទួលខុសត្រូវទូលាយជាងគេនោះ គឺការទទួលខុសត្រូវចំពោះសកម្មភាពផ្សេងៗ ដែលបានព្រមព្រៀង អាចនៅក្នុងពេលកំពុងរៀបចំផែនការ ឬរៀបចំគម្រោង និងអាច

39
40

00238432

D99/3/24



នៅពេលផែនការនោះចេញជារូបរាងដោយឥតព្រាងទុក ក្នុងខណៈដែលអ្នកចូលរួមសកម្មភាពទាំងអស់មានចេតនារួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដោយព្រមព្រៀង ដោយមិនគិតថាតើជនត្រូវចោទគឺជាជនដែលដល់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬមិនមែនជាជនដែលដល់នោះទេ។ អ្នកចូលរួមសកម្មភាពទាំងនោះត្រូវតែទទួលខុសត្រូវ ទោះបីជាពួកគេមានតួនាទី និងមុខងារក្នុងការអនុវត្តផែនការឧក្រិដ្ឋនោះជាអ្វីក៏ដោយ។ លើសពីនេះទៅទៀត ថ្មីៗនេះ អង្គជំនុំជម្រះឧទ្ធរណ៍ ICTY បានបញ្ជាក់ផងដែរថា ទម្រង់ទាំង៣នៃ JCE ដែល បុគ្គលប្រព្រឹត្តអំពើពិរុទ្ធ (*actus reus*) នៃបទក្រិដ្ឋមិនចាំបាច់ជាសមាជិក JCE នោះទេ ឲ្យតែបទឧក្រិដ្ឋដែលបាន ប្រព្រឹត្តនោះជាផ្នែកមួយនៃគោលបំណងរួម[41]។

២៤. ទម្រង់ទី២នៃការទទួលខុសត្រូវ ដែលមានលក្ខណៈខុសគ្នាពីទម្រង់ទី១ អនុវត្តចំពោះបុគ្គលទាំងឡាយណាដែលបានបំពេញកាតព្វកិច្ចទៅតាមផែនការបទឧក្រិដ្ឋ នៅក្នុងរចនាសម្ព័ន្ធស្ថាប័នមួយដូចជា ការឃុំឃាំង ឬមន្ទីរប្រមូលផ្តុំជាដើម[42]។ ទម្រង់ "ជាប្រព័ន្ធ" នៃ JCE នេះមិនតម្រូវឲ្យមានភស្តុតាងបញ្ជាក់ពីផែនការ ឬការព្រមព្រៀង (ទោះជាកើត ឬមិនកើតឡើងដោយឯកឯងក៏ដោយ)[43]។ ជាក់ស្តែង នៅក្នុងមន្ទីរឃុំឃាំង ដែលអ្នកជាប់ឃុំត្រូវបានគេធ្វើបាប ធ្វើទារុណកម្ម មិនត្រឹមតែប្រធានមន្ទីរប៉ុណ្ណោះទេដែលត្រូវទទួលខុសត្រូវ ជនដែលជាជំនួយការជាន់ខ្ពស់ និងអ្នកដែលធ្វើទារុណកម្ម និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀតដោយផ្ទាល់នោះ ក៏ត្រូវចូលរួមទទួលខុសត្រូវផងដែរ។ ជនទាំងឡាយដែលបំពេញតួនាទីរដ្ឋបាល ដែលជាតួនាទីចាំបាច់ដើម្បីសម្រេចគោលដៅសំខាន់ៗរបស់មន្ទីរ ឧទាហរណ៍ ចុះឈ្មោះជនជាប់ឃុំដែលទើបនឹងចូលមកថ្មី ធ្វើកំណត់ហេតុពីការស្លាប់ ផ្តល់ថ្នាំសង្កូវសម្រាប់ការព្យាបាល ផ្តល់ចំណីអាហារ ឬឃាមកាមមិនឲ្យអ្នកជាប់ឃុំចេញពីមន្ទីរ ក៏អាចត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែរ។ ពួកគេត្រូវតែទទួលខុសត្រូវនេះ ដោយសារពួកគេបានដឹងអំពីការរំលោភបំពាននានា ដែលបានកើតមាន និងមានចេតនាចូលរួមសកម្មភាព នៅក្នុងរចនាសម្ព័ន្ធរបស់ស្ថាប័ន។ ការទទួលខុសត្រូវបទព្រហ្មទណ្ឌអាចចាត់ទុកថាជាអំពើសមហេតុសមផល និងតាមដំណើរនៃធម្មជាតិ។ ពួកគេបានចូលរួមចំណែកប្រព្រឹត្តបទឧក្រិដ្ឋ ដោយសារពួកគេបំពេញតួនាទីផ្នែករដ្ឋបាល ឬបំពេញកាតព្វកិច្ចផ្សេងៗទៀត។ ប្រសិនបើគ្មានការគាំទ្រពីពួកគេ បទឧក្រិដ្ឋក៏មិនអាចកើតឡើងបានឡើយ។

41
42
43

ដូច្នេះ ទោះជាមានតួនាទីមិនសូវសំខាន់ក៏ដោយ ក៏ពួកគេរួមចំណែកជាសហការីថ្នាក់ក្រោម ដែលមិនអាចអត់បាននៅក្នុងយន្ដការមនុស្សឃាត។

២៥. ចំពោះទម្រង់នៃការទទួលខុសត្រូវបែបនេះ តុលាការប្រកាន់ខ្ជាប់តាមផ្លូវច្បាប់ថា អ្នកចូលរួមម្នាក់ៗ នៅក្នុងផែនការឧក្រិដ្ឋកម្មជារួមនេះ មិនគ្រាន់តែបានដឹងពីបទឧក្រិដ្ឋដែលសមាជិក ឬស្ថាប័នរបស់ខ្លួនពាក់ព័ន្ធ ប៉ុណ្ណោះទេ ថែមទាំងបានចូលរួម ទោះជាបានសម្ដែង ឬមិនបានសម្ដែងចេញ ថាមានឆន្ទៈឧក្រិដ្ឋ ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋបែបនោះក្ដីក៏ដោយ[44]។ ពួកគេមិនអាចនិយាយថាមិនបានដឹងរឿងអ្វីនោះទេ ព្រោះថាបុគ្គលណាមួយក៏ដោយ ដែលបំពេញកាតព្វកិច្ចមួយដែលអាចមានផលអាក្រក់នៅក្នុងស្ថាប័ន អាចបដិសេធមិន ចូលរួមនៅក្នុងសកម្មភាពបទឧក្រិដ្ឋ ដោយការចាកចេញពីស្ថាប័ននោះ។ មានការលើកលែងចំពោះ ជនដែលគ្រាន់តែជាអ្នកសំអាតផ្លូវដើរ ឬអ្នកបោកគក់សំលៀកបំពាក់ ដោយសារតែពួកគេមិនបានចូលរួមចំណែកសំខាន់ក្នុងការសម្រេចគោលបំណងបទឧក្រិដ្ឋរួមទេ។

២៦. ទម្រង់ទីពានៃការទទួលខុសត្រូវពាក់ព័ន្ធនឹងអ្នកចូលរួមទាំងឡាយ ដែលបានយល់ស្របទៅនឹងគោលដៅសំខាន់ នៃផែនការបទឧក្រិដ្ឋរួម ដូចជា ផែនការបណ្ដេញប្រជាពលរដ្ឋចេញដោយបង្ខំពីទីកន្លែងដែលពួកគាត់រស់នៅ។ អ្នកចូលរួមក្នុងឧក្រិដ្ឋកម្មទម្រង់ទី៣ នេះមិនចាំបាច់មានចេទនាដែលថា ចារីម្នាក់ ឬច្រើននាក់ក្នុងក្រុមឧក្រិដ្ឋកម្មផ្សេងៗទៀត ដំណាលគ្នានឹងការប្រព្រឹត្តិឧក្រិដ្ឋចំបង ដូចជាការបង្កឲ្យមានរបួស្នាម ឬការស្លាប់ជនស៊ីវិល ក្នុងដំណើរការជម្លៀសប្រជាជនចេញពីទកន្លែងដែលពួកគាត់រស់នៅ។ អ្នកចូលរួមសកម្មភាពអាចអាចជាអ្នកទទួលខុសត្រូវចំពោះទម្រង់នេះ តែក្នុងករណីដែលថាអ្នកចូលរួមសកម្មភាព មិនមានចេតនាប្រព្រឹត្តបទល្មើស "ដោយចៃដន្យ" នោះទេ ក៏ប៉ុន្តែជាអ្នកដែលមានតួនាទី អាចប្រមើលមើលដឹងពីការប្រព្រឹត្តិ និងមានបំណងទទួលយកហានិភ័យ ដែលបណ្ដាលមកពីការប្រព្រឹត្តិនោះ។ ឧទាហរណ៍ជាក់ស្ដែងមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិស្ដីពីការទទួលខុសត្រូវក្នុងទម្រង់នេះ ចំពោះអំពើប្លន់ប្រដាប់អាវុធនៅធនាគារមួយ ដែលមានជនពី៣ ឬច្រើននាក់ទៀតបានយល់ព្រមទៅប្លន់ធនាគារដោយយកកាំភ្លើងទៅជាមួយ។ ពួកគេមិនមានចេតនាសម្លាប់នរណាម្នាក់ទាល់តែសោះ ហើយក៏ព្រមព្រៀងគ្នាថានឹងមិនសម្លាប់ដែរ (អាចនឹងបានព្រមព្រៀងគ្នាថាមិនសម្លាប់ ឬក៏ថាកាំភ្លើងទុកសម្រាប់តែគម្រាមប៉ុណ្ណោះ)។ នៅពេលកំពុងប្លន់ ជនម្នាក់ក្នុងចំណោមនោះ បានសម្លាប់អ្នកបើកប្រាក់ម្នាក់។ នៅក្នុងស្ថានភាពបែបនេះ សមាជិកទាំងអស់ដែលចូលរួមក្នុង JCE ត្រូវទទួល

[44]

ខុសត្រូវចំពោះការសម្លាប់ ពីព្រោះវាជាផលវិបាកមួយដែលអាចប្រមើលទុកជាមុនដឹង ថា ប្រសិនកាន់កាំភ្លើង អាចនឹងមានមនុស្សស្លាប់ (ដោយមិនចាំបាច់មានចេតនាសម្លាប់នោះទេ)។ ការសម្លាប់កើតឡើង "ដោយគ្មានចេតនា" ប៉ុន្តែជាការស្លាប់ ដែលគេបានដឹងថាអាចនឹងកើតឡើងបាន។ ឧទាហរណ៍មួយទៀត ក្រុមចោរប្លន់មួយក្រុមដែលបានព្រមព្រៀងគ្នាទៅប្លន់ធនាគារមួយ ដោយមិនមានចេតនាសម្លាប់នរណាម្នាក់ទាល់តែសោះ ដូច្នេះពួកគេក៏ប្រើប្រាស់អាវុធក្លែងក្លាយដើម្បីបន្លំភ្នែក។ ប៉ុន្តែនៅក្នុងក្រុមនេះ មានសមាជិកម្នាក់ បានលួចយកអាវុធមែនទែនទៅដោយសម្ងាត់ ដាក់តាមខ្លួនដើម្បីទៅប្លន់ធនាគារដោយមានបំណងចង់សម្លាប់មនុស្ស ប្រសិនបើចាំបាច់។ ប្រសិនបើមានអ្នកចូលរួមសកម្មភាពមួយផ្សេងទៀតក្នុងផែនការបទឧក្រិដ្ឋរួមមួយនេះ ឃើញអ្នកដែលជាសមាជិករបស់ ខ្លួនលាក់លៀមអាវុធទាំងនោះ។ ប្រសិនបើជនប្រដាប់អាវុធបាញ់សម្លាប់អ្នកបើកប្រាក់ ឬអ្នកធ្វើការនៅធនាគារក្នុងពេលកំពុងធ្វើសកម្មភាព ជនម្នាក់ដែលបានឃើញថាវីយកអាវុធមែនទែននោះ អាចនឹងត្រូវទទួលខុសត្រូវចំពោះអំពើប្លន់ និងការសម្លាប់ ដូចអ្នកសម្លាប់ដែរ ចំណែកសមាជិកផ្សេងទៀតអាចទទួលខុសត្រូវតែចំពោះអំពើប្លន់ប្រដាប់អាវុធតែប៉ុណ្ណោះ។ វាជាការពិត ដែលជននោះស្ថិតនៅក្នុងស្ថានភាពមួយដែលអាចរំពឹងទុកជាមុនពីភាពជាក់លាក់ដែលសមហេតុផល ដែលជនប្រដាប់ដោយអាវុធមែនទែនម្នាក់នោះ អាចនឹងប្រើអាវុធដើម្បីសម្លាប់មនុស្ស ប្រសិនបើកើតមានបញ្ហាក្នុងពេលធ្វើសកម្មភាពប្លន់។ ទោះបីជាគាត់មិនមានចេតនាប្រព្រឹត្តឧក្រិដ្ឋក៏ដោយ ក៏គាត់បានមើលឃើញមុនរួចជាស្រេចពីហេតុការណ៍ ហើយមានចេតនាទទួលយកហានិភ័យដែលអាចកើតមាន។ តាមពិតគាត់អាចប្រាប់ទៅចោរប្លន់ឯទៀតថា ពិតជាមានគ្រោះថ្នាក់ ដោយការសម្លាប់មនុស្សជាក់ជាមិនខាន។ ដូចនេះ គាត់ក៏អាចយកអាវុធចេញពីចោរប្លន់រូបនោះដែរ ឬក៏អាចដកខ្លួនចេញពីសកម្មភាពប្លន់នោះតែម្តង ឬក៏ឈប់ធ្វើជាសមាជិកក្នុងក្រុមនោះតែម្តង។ គេអាចនិយាយបានថា ដើម្បីឲ្យការទទួលខុសត្រូវព្រហ្មទណ្ឌក្រោមទម្រង់ទី៣នៃ JCE កើតឡើងបាន លុះណាតែបទឧក្រិដ្ឋដែលមិនស្ថិតនៅក្នុងផែនការរួម បានកើតឡើងក្នុងសកម្មភាពប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលបានព្រមព្រៀងរួចហើយ។ លើសពីនេះទៅទៀត វាក៏មានសារៈសំខាន់ផងដែរ ដែលអ្នកប្រព្រឹត្តឧក្រិដ្ឋទី២មានឱកាសក្នុងការគិតទុក ជាមុនចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋដែលមិនបានព្រមព្រៀង ដោយអ្នកប្រព្រឹត្តឧក្រិដ្ឋទី១"[45]។ ឧទាហរណ៍ ប្រសិនបើអង្គភាពកងទ័ពមួយចូលមកកាន់កាប់ភូមិមួយក្នុងគោលបំណងឃុំខ្លួនមនុស្សស្រីគ្រប់រូប ព្រមទាំងដាក់ពួក

45

គេជាទាសករទៀតនោះ ការរំលោភធ្វើឡើងដោយកងទ័ពម្នាក់ក្នុងអង្គភាពនោះ ក៏នឹងរាប់បញ្ចូលថាជាការដាក់ជាទាសករដែរ ពីព្រោះការចាត់ទុកមនុស្សមានជីវិតដូចជាវត្ថុ អាចងាយនឹងឈានទៅដល់ការចាប់រំលោភណាស់។ ទោះជាយ៉ាងណាក៏ដោយ "អ្នកប្រព្រឹត្តឧក្រិដ្ឋទី២" ចាំបាច់ត្រូវប្រមើលទុកជាមុនឱ្យបានជាក់លាក់អំពីលទ្ធភាពនៃការរំលោភ (ត្រូវតែមានអ្វីមកបញ្ជាក់ពីស្ថានការណ៍ ឬយ៉ាងហោចណាស់ ដោយពិចារណាទៅលើអង្គហេតុជាក់ស្តែងនៃករណីនីមួយៗ) ឬយ៉ាងហោចណាស់ ស្ថិតក្នុងស្ថានភាព "នៃមនុស្សដែលមានការអង្កេតដោយមានការយកចិត្តទុកដាក់" ដើម្បីជាការប្រមើលទុកថា ពិតជាអាចមានការរំលោភមែន។ ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដោយចៃដន្យនេះ យោងទៅលើការមើលឃើញទុកជាមុន និងហានិភ័យ គឺទម្រង់នៃការទទួលខុសត្រូវដែលជាផលវិបាក (និងដោយចៃដន្យ) នៃផែនការឧក្រិដ្ឋកម្មរួម ដែលជាការព្រមព្រៀង ឬផែនការរបស់បុគ្គលជាច្រើន ដែលពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់។ "បទឧក្រិដ្ឋបន្ថែម" គឺមាននៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួមដែលអ្នកចូលរួមម្នាក់ៗទទួលខុសត្រូវរួចជាស្រេចតទៅហើយ។ "បទឧក្រិដ្ឋបន្ថែម" នេះអាចកើតមានបាន ក៏ដោយសារតែមានការចូលរួមធ្វើផែនការក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដូចដែលបានព្រមព្រៀងជាមុនរួចហើយ។ បើគ្មានការព្រមព្រៀងគ្នាប្រព្រឹត្តឧក្រិដ្ឋកម្មរួមនោះទេ ការប្រព្រឹត្តិបទឧក្រិដ្ឋ "ដោយចៃដន្យ" ឬ "ដោយបន្ថែម" ក៏មិនអាចនឹងកើតមានឡើងបានដែរ។ វាមានទំនាក់ទំនងហេតុនិងផលរវាងការកកើតឡើងនូវបទល្មើសបន្ថែមបែបនោះ និងបទឧក្រិដ្ឋដែលបានព្រមព្រៀងជាមុន ការយល់ដឹងអំពីបទឧក្រិដ្ឋរបស់អ្នកប្រព្រឹត្តទី២ ដែលដឹងថាបទល្មើសបន្ថែមមួយអាចនឹងនឹងកើតមានឡើង និងការខកខានរបស់គាត់ក្នុងការរារាំង ឬបញ្ឈប់មិនឱ្យបទឧក្រិដ្ឋទី១នោះកើតឡើង។ បទល្មើសបន្ថែមត្រូវបានបញ្ជាក់ឱ្យដឹងច្បាស់ នៅដំណាលគ្នានៃការព្រមព្រៀងប្រព្រឹត្តបទឧក្រិដ្ឋរួម ហើយបទល្មើសបន្ថែមអាចនឹងកើតឡើងណាស់ដោយការពិតដែលថា អ្នកចូលរួមនៅក្នុង JCE ដែលមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមមិនត្រូវបានបញ្ឈប់ ដោយអ្នកចូលរួមសកម្មភាព ដែលបានដឹងអំពីភវនីយភាពនៃបទឧក្រិដ្ឋបន្ថែម (ហើយមិនបានបោះបង់ផែនការឧក្រិដ្ឋកម្មរួម ដោយភ័យខ្លាចអំពីការកើតមានបទឧក្រិដ្ឋបន្ថែមនោះឡើយ)។ ជាការពិតណាស់ថា ទង្វើរបស់អ្នកប្រព្រឹត្តឧក្រិដ្ឋទី២ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កឱ្យបទល្មើសបន្ថែមអាចកើតឡើងបាន។

២៧. ដូច្នេះ បន្ថែមលើចេតនានៃការចូលរួម ចេតនាធ្វើមិនដឹងមិនឮ (dolus eventualis) - ដែលជាបញ្ញត្តិក្នុងច្បាប់ស៊ីវិល ដែលមានលក្ខណៈស្រដៀងទៅនឹងបញ្ញត្តិ ចេតនាធ្វើមិនដឹងមិនឮ

(adertent recklessness) ក្នុងច្បាប់កុំមិន (common law) ដែរ - អាចជាបន្ទុកគ្រប់គ្រាន់សម្រាប់ឲ្យអ្នកចូលរួមក្នុងផែនការរួម និង "មានចេតនាទទួលយកហានីភ័យ" ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទល្មើសបន្ថែម រួចទៅហើយ"[46]។ ឧបមាថា មានសមាជិកខ្លះនៃអង្គភាពយោធាសម្រេចឃុំខ្លួនក្រុមប្រជាពលរដ្ឋជាស្ត្រីដែលជាបច្ចាមិត្ត ដោយសង្ស័យថាមានការពាក់ព័ន្ធនៅក្នុងការវាយប្រហារដោយអាវុធ ហើយឃុំខ្លួនពួកគេទាំងនោះក្នុងស្ថានភាពអមនុស្សធម៌ និងថោកទាប។ ឧបមាទៀតថា មានសមាជិកម្នាក់ ឬច្រើននាក់ដឹងយ៉ាងច្បាស់ថាសហការី ឬច្រើននាក់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ដោយបានប្រព្រឹត្តបទល្មើសដោយការរំលោភច្រើនលើកច្រើនសារ ព្រមទាំងបានបញ្ជាក់យ៉ាងច្បាស់ថា ឲ្យតែមានឱកាសរំលោភស្ត្រីជាបច្ចាមិត្ត គឺគាត់នឹងរំលោភឲ្យខាងតែបាន។ ឧបមាទៀតថា សមាជិកម្នាក់នេះ នៃអង្គភាពនោះពិតជាបានរំលោភនារីជាច្រើននាក់ ក្នុងពេលស្ថិតក្នុងឃុំខ្លួនក្នុងស្ថានភាពខុសច្បាប់។ ក្នុងករណីនេះ សមាជិកម្នាក់ ឬច្រើននាក់ផ្សេងទៀត ដែលបានដឹងច្បាស់អំពីភវនីយភាព ដែលថាការរៀបចំឲ្យមានស្ថានភាពនៃការឃុំឃាំងបែបនេះ គឺជាកត្តាជំរុញឲ្យសមាជិករូបនោះអាចរំលោភនារីនោះបាន ត្រូវទទួលខុសត្រូវទាំងការធ្វើបាបដោយអមនុស្សធម៌ និងទាំងការរំលោភផងដែរ។ សហគមន៍អន្តរជាតិត្រូវធ្វើយ៉ាងណាមិនឲ្យការប្រព្រឹត្តបទល្មើសបែបនេះកើតឡើងដោយការតម្រូវឲ្យជនដែលប្រព្រឹត្តបទល្មើសទាំងនោះទទួលខុសត្រូវទាំងស្រុង។ កម្រិតខុសគ្នានៃពិរុទ្ធភាព អាចនឹងត្រូវពិចារណា នៅក្នុងដំណាក់កាលនៃការសម្រេចផ្តន្ទាទោស[47]។

២៨. ការទទួលខុសត្រូវក្នុងសហកម្មឧក្រិដ្ឋកម្មរួមទាំងបីទម្រង់ មានលក្ខណៈខុសប្លែកពីការទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចជាការទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មនៃ ការជួយទំនុកបំរុងជាដើម។ ទ្រឹស្តី JCE មានគោលបំណងសំខាន់ផ្តន្ទាទោសកំហុសអ្នកចូលរួមទាំងអស់នៅក្នុងបរិបទនៃការប្រព្រឹត្តបទឧក្រិដ្ឋរួម។ មានការខុសប្លែកគ្នាចំនួន២យ៉ាង រវាងការជួយទំនុកបំរុង និងការទទួលខុសត្រូវក្នុងJCE:

i. *អំពើពិរុទ្ធ (Actus Reus):* ការរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋគឺជាលក្ខខណ្ឌចាំបាច់ ដើម្បីឲ្យចារីមានការទទួលខុសត្រូវក្នុងប្រភេទបទឧក្រិដ្ឋ នៃការជួយទំនុកបំរុង។ រីឯការទទួលខុសត្រូវក្នុង JCE វិញ មិនចាំបាច់ឲ្យចារីរួមចំណែកដ៏សំខាន់ក្នុងការប្រព្រឹត្តនោះទេ ពោលគឺវាមានលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យចារីទទួលខុសត្រូវរួចទៅ

46

47

ហើយ ប្រសិនបើអង្គហេតុទាំងឡាយជាដើមហេតុក្នុងការអនុវត្តនូវផែនការរួម[48]។ បច្ចុប្បន្ននេះ ICTY បានបកស្រាយថា ការចូលរួមត្រឹមកម្រិតនេះ គឺជាការចូលរួម "ដ៏សំខាន់" [ដែលនាំឲ្យមានបទល្មើស] (សូមមើល *Brdanin* អង្គជំនុំជម្រះឧទ្ធរណ៍ កថាខណ្ឌ ៤២៧)។ គួរកត់សម្គាល់ផងដែរថា ជនត្រូវចោទមិនចាំបាច់ធ្វើសកម្មភាពដោយផ្ទាល់ចំពោះផ្នែកណាមួយនៃអំពើពិរុទ្ធនោះទេ។

ii. បំណងឧក្រិដ្ឋ: បុរេលក្ខខណ្ឌនៃបំណងឧក្រិដ្ឋ នៃការទទួលខុសត្រូវក្នុងបទឧក្រិដ្ឋនៃការជួយទំនុកបំរុង គឺគ្រាន់តែជាការដឹងឮថា អំពើដែលបានប្រព្រឹត្តពិតជាបច្ច័យដល់ការប្រព្រឹត្តបទឧក្រិដ្ឋ។ ចំណែកឯការទទួលខុសត្រូវក្នុង JCE វិញ បំណងឧក្រិដ្ឋត្រូវមានលក្ខណៈច្បាស់លាស់ជាងនេះ ពោលគឺ ទាល់តែ[ចារី] នោះមានចេទនាសម្រេចគោលបំណងរួម ឬមានចេទនាសម្រេចគោលបំណងរួម និងការប្រមើលឃើញថា ឧក្រិដ្ឋផ្សេងៗទៀតក្រៅអំពីឧក្រិដ្ឋរួមក៏អាចនឹងកើតឡើងផងដែរ[49]។

អង្គជំនុំជម្រះឧទ្ធរណ៍ ICTY បានពន្យល់បកស្រាយថា ការញែកឲ្យដាច់ពីគ្នារវាងការទទួលខុសត្រូវក្នុងបទឧក្រិដ្ឋជួយទំនុកបំរុង និងការទទួលខុសត្រូវក្នុង JCE មានសារសំខាន់ ដើម្បីធ្វើការបកស្រាយទម្ងន់នៃទោសឧក្រិដ្ឋឲ្យបានត្រឹមត្រូវ និងសម្រាប់ជាមូលដ្ឋានក្នុងការផ្តន្ទាទោស ដោយហេតុថាជាទូទៅស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋនៃការជួយទំនុកបំរុងស្រាលជាងស្ថានទម្ងន់ទោសនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម[50]។

២៩. ដោយទ្រឹស្តី JCE ពឹងផ្អែកលើបញ្ញត្តនៃចេតនា ឬចេតនានិងការប្រមើលដឹងជាមុន និងទ្រឹស្តី JCE ក៏ផ្អែកលើទំនាក់ទំនងហេតុនិងផល ដូច្នេះទ្រឹស្តី JCE ក៏ដូចគ្នានឹងទ្រឹស្តីដែលមានចែងក្នុងច្បាប់ជាតិស្តីពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរួម (ទោះបីជាក្នុងប្រព័ន្ធជាតិ ត្រូវពឹងផ្អែកលើបញ្ញត្តិមួយចំនួន ដូចជា សហចារីកម្ម និងការសមគំនិត។

**ខ. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ**

៣០. បញ្ញត្តនៃ JCE មានសារសំខាន់ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាងច្បាប់ជាតិ។ ក្នុងសហគមន៍អន្តរជាតិ បទឧក្រិដ្ឋអន្តរជាតិ ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍ មានលក្ខណៈរួមដូចគ្នាមួយ។ បទឧក្រិដ្ឋទាំងនេះជា

48

49

50

សណ្ឋានផ្សេងគ្នានៃអំពើព្រហ្មទណ្ឌជារួម ដែលនៅក្នុងនោះ បទឧក្រិដ្ឋទាំងនោះត្រូវបានធ្វើឡើង ដោយបុគ្គលមួយក្រុម កងយោធា ឬមន្ត្រីរាជការ ដែលធ្វើឡើងដោយឯកឆន្ទ ឬដើម្បីគោរពទៅតាមគោលការណ៍[51]។ នៅពេលបទឧក្រិដ្ឋបែបនេះត្រូវបានប្រព្រឹត្ត គេពិតជាមានការលំបាកក្នុងការកំណត់ការចូលរួមចំណែកជាក់លាក់ របស់អ្នកចូលរួមសកម្មភាពម្នាក់ៗនៅក្នុងផែនការព្រហ្មទណ្ឌរួមនេះណាស់ ដោយហេតុថា (i) អ្នកចូល រួមសកម្មភាពទាំងអស់មិនបានប្រព្រឹត្តដូចៗគ្នា តែពួកគេជាអ្នកបានចូលរួមក្នុងតួនាទីផ្សេងៗគ្នា នៅក្នុងការធ្វើផែនការ ការរៀបចំ ការញុះញង់ ការចាត់ចែង ការអនុវត្ត ឬពួកគេ ចូលរួមចំណែកក្នុងការប្រព្រឹត្តិសកម្មភាពព្រហ្មទណ្ឌណាមួយផ្សេងទៀត និង(ii) ភស្តុតាងដែលពាក់ព័ន្ធការប្រព្រឹត្តិសកម្មភាពរបស់បុគ្គលម្នាក់ៗ មិនអាចរកបាន ឬអាចរកបានដែរ តែបានដោយលំបាកជាទីបំផុត។

៣១. ការពិចារណាទាំងអស់នេះ យកមកអនុវត្តដោយមានមូលដ្ឋានកាន់តែរឹងមាំជាងនេះ ចំពោះឧក្រិដ្ឋកម្មផ្សេងៗដូចជាឃាតកម្ម អំពើបំពារបំពានធ្ងន់ធ្ងរ ប្រព្រឹត្តដោយហ្វូងមនុស្សដែលមានគ្នាច្រើន។ ក្នុងករណីបែបនេះ ការប្រមូលភស្តុតាងបញ្ជាក់អំពីការចូលរួមពិតប្រាកដរបស់សមាជិកណាមួយក្នុងចំណោមហ្វូងមនុស្សដែលប្រព្រឹត្តបទឧក្រិដ្ឋនោះ កាន់តែលំបាក។ ការពិចារណាដូចគ្នានេះ ក៏ជាការមួយត្រឹមត្រូវសម្រាប់ករណីដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងជាលក្ខណៈស្ថាប័ននៅក្នុងអង្គភាពឋានានុក្រម និងអង្គភាពចាត់តាំង មានដូចជាជំរុំប្រមូលផ្តុំ ឬជំរុំបង្ខាំងមនុស្ស ជាដើម ដែលយើងពិបាកនឹងចង្អុលបង្ហាញអំពីតួនាទីពិតប្រាកដរបស់បុគ្គលនីមួយៗដែលធ្វើការងារនៅក្នុងអង្គការនោះ ឬធ្វើការងារឱ្យអង្គការនោះណាស់ ។

៣២. ការធ្វើឱ្យការទទួលខុសត្រូវមានភាពមិនច្បាស់លាស់ ក្នុងដុំពពកខ្មៅនៃការប្រព្រឹត្តិបទឧក្រិដ្ឋរួម និងមិនវិនិច្ឆ័យទោសអ្នកប្រព្រឹត្តបទឧក្រិដ្ឋនោះ គឺជាអំពើអសីលធម៌ និងផ្ទុយពីវត្ថុបំណងរួមនៃច្បាប់ព្រហ្មទណ្ឌ ដែលត្រូវការពារសហគមន៍មិនឱ្យមានការប្រព្រឹត្តិខុស ដែលការប្រព្រឹត្តិខុសទាំងនោះបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ប្រយោជន៍រួម។ ការខូចខាតតែងតែមានលក្ខណៈធ្ងន់ធ្ងរជារឿយៗក្នុងបរិបទការប្រព្រឹត្តិឧក្រិដ្ឋកម្មរួម។ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ក៏ដូចជាប្រព័ន្ធភាវូបនីយកម្ម នៃគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់កំណើតចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី២ ដែលជាយាននៃការទទួលខុសត្រូវចំពោះព្យសនកម្មទាំងពួង។

51

**II. គោលការណ៍នៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម ដែលមានចែងយ៉ាងច្បាស់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនអំឡុងឆ្នាំ១៩៧៥**

៣៣. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម គឺផ្អែកទៅលើវិធាន និងគោលការណ៍ច្បាប់ជាតិ និងសេចក្តីសម្រេចតាមផ្លូវតុលាការអន្តរជាតិ និងបញ្ញត្តិច្បាប់ដែលត្រូវបានកំណត់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងក្រោយសង្គ្រាមលោកលើកទី២[52]។ សារជាតិទំនៀមទម្លាប់នៃវិធានអន្តរជាតិទាំងអស់នេះ ត្រូវបានបង្កើតឡើងមុនរយៈកាលនៃឧក្រិដ្ឋកម្មឆ្នាំ១៩៧៥-១៩៧៩ ដែលត្រូវបានយកមកពិចារណាដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈច្បាប់យុត្តិសាស្ត្រផ្អែកលើ (i) ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ ("ធម្មនុញ្ញ Nuremberg") និង (ii) ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ ឆ្នាំ១៩៤៥។ ដូច្នេះ ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម គឺមិនមែនជាការបង្កើតសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយុហ្គោស្លាវីទេ[53]។ ប៉ុន្តែ រដ្ឋអាជ្ញាតទល់នឹង Tadić បានបំភ្លឺអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មរួមដោយការធ្វើសំយោគរវាងវិធាន ដែលត្រូវបានគេយកមកអនុវត្តពីមុន និងគោលការណ៍ផ្សេងៗ ឱ្យទៅក្នុងក្របខ័ណ្ឌជាប្រព័ន្ធ និងដែលទាក់ទងជាមួយគ្នាជារួម[54]។

៣៤. ការបែងចែកទម្រង់ការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសាលក្រមTadić ឆ្នាំ១៩៩៩ គឺជាការប៉ុនប៉ងធ្វើសនិទានកម្មលើសេចក្តីសម្រេចខុសៗគ្នាជាច្រើន និងដើម្បីកំណត់សនិទានភាពនៃសេចក្តីសម្រេចនីមួយៗ។ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម តម្រូវឱ្យបុគ្គលទាំងឡាយទទួលខុសត្រូវចំពោះការរួមគ្នាប្រព្រឹត្តបទល្មើស បើទោះបីជាឧក្រិដ្ឋកម្មនេះបានដោយចារី តែមួយចំនួន (ឬអ្នកដែលមនុស្សក្នុងក្រុមនោះបានប្រើ) ដោយផ្ទាល់ ក៏ដោយ ពីព្រោះថា ប្រព័ន្ធច្បាប់គួរទប់ស្កាត់ រកវិធីដោះស្រាយណាកុំឱ្យមានការចូលរួមក្នុងចេតនាបទឧក្រិដ្ឋកម្ម។ មធ្យោបាយតែមួយ ដើម្បីធ្វើបានដូច្នោះ គឺឱ្យអ្នកចូលរួមប្រព្រឹត្តបទឧក្រិដ្ឋទទួលទោសចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋដោយចេតនា ព្រមទាំងឱ្យទទួលនូវផលវិបាកដែលអាចប្រមើលឃើញ ចំពោះការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ។

52

53

54

**ក. ការវិវត្តន៍នៃបញ្ញត្តសហកម្មឧក្រិដ្ឋកម្មរួម**

៣៥. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចក្លាយមកពីកម្រងឯកសារនៃអំពើ និងឥរិយាបទផ្សេងៗគ្នា ដូចជាការអនុវត្តន៍ច្បាប់របស់រដ្ឋ សន្ធិសញ្ញា និងលិខិតុបករណ៍អន្តរជាតិផ្សេងៗ ការអនុវត្តន៍របស់អង្គការអន្តរជាតិ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ និងសេចក្តីសម្រេចរបស់តុលាការជាតិ និងអន្តរជាតិ ជាដើម។ ក្នុងបរិបទច្បាប់មនុស្សធម៌អន្តរជាតិអំពីជម្លោះប្រដាប់អាវុធ លក្ខណៈវិនិច្ឆ័យ ចំពោះការអនុវត្តន៍គ្រប់ទីកន្លែង អាចត្រូវបានធ្វើឱ្យមិនមានលក្ខណៈច្បាស់លាស់ ហើយការយល់ឃើញអំពីយុត្តិធម៌ ត្រូវបានបែកខ្ញែកពីគ្នា និងលើកតម្កើងចាត់ទុកជាមូលដ្ឋានមួយ ដោយសារតែខនៅក្នុង Martens Clause ដែលដាក់បញ្ចូលដំបូងគេទៅក្នុងបុព្វកថានៃអនុសញ្ញាក្រុងហ្សឺណែវ II ឆ្នាំ១៨៩៩ ហើយក្រោយមកត្រូវបានសង្ខេបនៅក្នុងសន្ធិសញ្ញាមួយចំនួន រួមទាំងអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងសាលក្រមតុលាការជាតិ និងអន្តរជាតិជាច្រើនទៀត[55]។ ខ នោះផ្តល់ជាសេចក្តីសន្និដ្ឋាន ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានមកពីការអនុវត្តដ៏មានសង្គតភាព និងទូលំទូលាយរបស់រដ្ឋផង និងបានមកពីតម្រូវការសីលធម៌ និងសង្គមសម្រាប់ការគោរពវិធានទាំងនោះផង និងទស្សនៈផ្លូវច្បាប់របស់រដ្ឋមួយចំនួនផង ឬនីតិស្ថាប័នអន្តរជាតិ អំពីគុណតម្លៃនៃការចងកាតព្វកិច្ចនៃគោលការណ៍ បើទោះបីជាគ្មានការអនុវត្តន៍របស់រដ្ឋដោយសង្គតភាព ឬទូលំទូលាយក៏ដោយ[56]។

៣៦. គោលការណ៍ដែលជាមូលដ្ឋាននៃការទទួលខុសត្រូវ ចំពោះសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានក្រោយសង្គ្រាមលោកលើកទី២ ខណៈពេលដែលសហគមន៍អន្តរជាតិ ដោះស្រាយកិច្ចការដ៏ធំទាក់ទិននឹងការកាត់សេចក្តីអំពើឃោរឃៅទៅលើហ្វូងមហាជន និងការប្រព្រឹត្តិបទឧក្រិដ្ឋរួម។ ក្នុងឆ្នាំ១៩៤៥ ប្រទេសជាច្រើន បានចូលរួមកិច្ចព្រមព្រៀងក្នុងការនាំខ្លួនឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃមហាអំណាចទាំង៣ ដើម្បីកាត់សេចក្តីរកយុត្តិធម៌[57]។ មាត្រាទី៦នៃធម្មនុញ្ញ Nuremberg បានត្រូវបង្កើតឡើងអនុលោមតាមកិច្ចព្រមព្រៀង ផ្តល់ឱ្យសាលាក្តីយោធាអន្តរជាតិនូវអំណាចកាត់ទោស និងផ្តន្ទាទោសជនទាំងឡាយណាដែលធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដល់ប្រទេសមហាអំណាចនៅអឺរ៉ុប មិនថាជាបុគ្គល ឬជាសមាជិកនៃអង្គការទេ ឱ្យតែបានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មាត្រាទី៦ នៃធម្មនុញ្ញ Nuremberg បានចែងថា៖

55

56

57

មេដឹកនាំ អ្នករៀបចំ អ្នកមេគំនិត និងអ្នកឃុបឃិត ដែលបានចូលរួមក្នុងការតាក់តែង ឬអនុវត្តន៍ផែនការរួមមួយ ឬឃុបឃិតប្រព្រឹត្តបទឧក្រិដ្ឋណាមួយក្នុងចំណោមបទឧក្រិដ្ឋ ដូចដែលបានរៀបរាប់ខាងលើនឹងត្រូវទទួលខុសត្រូវចំពោះទង្វើដែលអ្នកណាម្នាក់បានធ្វើក្នុងការអនុវត្តផែនការទាំងនោះ[58]។

៣៧. បញ្ញត្តនេះប្រមើលឃើញយ៉ាងច្បាស់អំពី (i) ការដាក់ឱ្យទទួលខុសត្រូវចំពោះការចូលរួមក្នុងផែនការឧក្រិដ្ឋមួយ ដោយមិនគិតថាផែនការនោះត្រូវបានអនុវត្ត ឬមិនទាន់បានអនុវត្តនៅឡើយនោះទេ ហើយ (ii) ការទទួលខុសត្រូវបទឧក្រិដ្ឋចំពោះទង្វើប្រព្រឹត្តដោយអ្នកចូលរួមផ្សេងនៅក្នុងការអនុវត្តន៍ផែនការឧក្រិដ្ឋនោះ។

៣៨. ធម្មនុញ្ញ Nuremberg ត្រូវបានគេដាក់ឈ្មោះថាជា "កំណើតនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" ហើយគោលការណ៍ Nuremberg នេះទៀតសោតក៏ត្រូវបានទទួលស្គាល់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទៀតផង[59]។ គោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញ Nuremberg បានត្រូវគេយកមកអនុវត្ត និងបង្រួបបង្រួមក្នុងការកាត់ក្តីជាច្រើនគ្រានៅNuremberg នៅសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា និងនៅក្នុងតំបន់ដែលគេកាន់កាប់មួយចំនួន[60]។ ធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិ សម្រាប់ចុងបូព៌ា យកគម្រូតាមធម្មនុញ្ញNuremberg ស្ទើរតែគ្រប់ពាក្យ រួមទាំងបញ្ញត្តដែលចែងថាអ្នកចូលរួមក្នុងការតាក់តែងផែនការរួមមួយ ឬការផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះរាល់ទង្វើដែលជាណាម្នាក់ធ្វើក្នុងការអនុវត្តន៍ផែនការរបស់ខ្លួន[61]។

៣៩. ធម្មនុញ្ញNuremberg ហាក់ដូចជាយកគម្រូតាម "ចរិកលក្ខណៈនៃយុត្តាធិការជាតិ" ខ្លះ ដែលប្រកាន់យកផែនការទូទៅនៃការប្រព្រឹត្តិបទល្មើស ដោយចាត់ទុកអ្នកចូលរួមក្នុងបទឧក្រិដ្ឋមួយថាជាសហចារីនៃឧក្រិដ្ឋកម្ម និងចាត់ទុកការខុសគ្នាក្នុងទំហំនៃការចូលរួមរបស់បុគ្គលម្នាក់ៗក្នុងឧក្រិដ្ឋកម្ម ថាជាបញ្ហាមួយដែលប៉ះពាល់ដល់ការកាត់ទោស តែមិនមែនជាបញ្ហាពិរុទ្ធភាព ឬភាពគ្មានទោសពៃរ៍នោះទេ[62]។

៤០. ដើម្បីផ្តល់អានុភាពដល់បញ្ញត្តិរបស់ធម្មនុញ្ញNuremberg និងដើម្បីឱ្យការចោទប្រកាន់ទៅលើឧក្រិដ្ឋជនសង្គ្រាមផ្សេងៗ និងជនល្មើសឯទៀតបានសម្រេច សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស បារាំង និងសហភាពសូវៀត បានអនុម័តច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ នៅថ្ងៃទី២០ ខែធ្នូ

58

59

60

61

62

ឆ្នាំ១៩៤៥[63]។ មាត្រាទីII (២) នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ នេះក៏បានទុកលទ្ធភាពឲ្យការចោទប្រកាន់ធ្វើឡើងបាន ពីបទឧក្រិដ្ឋប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងតំបន់ដែលគ្រប់គ្រងដោយមហាអំណាចសម្ព័ន្ធមិត្ត និងបានបង្កើតរបៀបនៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដូចខាងក្រោម។ ជនទាំងឡាយណាដោយមិនគិតពីសញ្ជាតិសមត្ថភាពដែលជននោះធ្វើ ត្រូវបានចាត់ទុកថាត្រូវបានប្រព្រឹត្តបទឧក្រិដ្ឋមួយ ដូចដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រានេះថា ប្រសិនបើជននោះជា (ក)ចារីមេ ឬ(ខ) ជាអ្នកសមគំនិតប្រព្រឹត្តបទឧក្រិដ្ឋណាមួយក៏ដោយ ឬបានបញ្ជា ឬញុះញង់ ឬ(គ) ចូលរួមចំណែក ឬ(ឃ) មានជាប់ពាក់ព័ន្ធនឹងផែនការ ឬក្រុមប្រព្រឹត្តបទឧក្រិដ្ឋ ឬ(ង) ជាសមាជិកនៃអង្គការ ឬក្រុមដែលមានជាប់ពាក់ព័ន្ធការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬ(ច) យោងតាមកថាខណ្ឌទី១ (ក) ប្រសិនបើជននោះមានមុខតំណែងនយោបាយខ្ពស់ ជាជនស៊ីវិល ឬយោធា (រាប់ទាំងអគ្គបញ្ជាការផង) នៅប្រទេសអាឡឺម៉ង់ ឬនៅក្នុងប្រទេសណាមួយដែលជាសម្ព័ន្ធមិត្ត សហសម្ព័ន្ធមិត្ត ឬប្រទេសវណប ឬមានមុខនាទីខ្ពស់ក្នុងជង្ហើមសេដ្ឋកិច្ច ឧស្សាហកម្ម ឬហិរញ្ញវត្ថុរបស់ប្រទេស[64]។

បញ្ញត្តនេះប្រមើលឃើញយ៉ាងច្បាស់នូវការទទួលខុសត្រូវបទឧក្រិដ្ឋចំពោះការចូលរួមក្នុងក្រុមប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈ (i)ការចូលរួមដោយស្ម័គ្រចិត្តក្នុងក្រុមប្រព្រឹត្តបទល្មើសទាំងអស់នេះ ឬក៏ (ii)មានជាប់ពាក់ព័ន្ធជាមួយផែនការឧក្រិដ្ឋរបស់មនុស្សមួយក្រុម ឬក្រុមប្រព្រឹត្តបទល្មើសដែលមានគ្នាច្រើន។ ទាំងចារី ទាំងអ្នកដែរដល់ និងជនណាដែលមានជាប់ពាក់ព័ន្ធនឹងផែនការ ឬក្រុមប្រព្រឹត្តបទល្មើស ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទឧក្រិដ្ឋ[65]។

៤១. លិខិតុបករណ៍ផ្លូវច្បាប់អន្តរជាតិទាំងនេះ និងយុត្តិសាស្ត្រ ផ្អែកលើបញ្ញត្តិ មានសារៈសំខាន់ដើម្បីស្វែងយល់អំពីគោលការណ៍ទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមដែលបានចែងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានពន្យល់ក្នុង Kupreskic:

គេមិនអាចប្រកែកបានទេថា គុណតម្លៃដ៏ឧត្តុង្គឧត្តមគួរត្រូវបានភ្ជាប់មកជាមួយសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចសាលាក្តីអន្តរជាតិNuremberg ឬTokyo ឬតុលាការ

63
64
65

ជាតិដែលដំណើរការដោយគុណធម៌ និងដោយអំណាចនៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ ច្បាប់នីតិបញ្ញត្តិដែលបានអនុម័តកាលពីឆ្នាំ១៩៤៥ ដោយមហាអំណាចទាំងបួន និងឆ្លុះបញ្ចាំងអំពីកិច្ចព្រមព្រៀងអន្តរជាតិ ក្នុងបណ្តាប្រទេសមហាអំណាច ស្តីពីច្បាប់ធរមានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងយុត្តាធិការតុលាការដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មទាំងនោះ។ តុលាការទាំងនេះប្រតិបត្តិការក្រោមលិខិតុបករណ៍អន្តរជាតិ ដែលមានចែងបញ្ញត្ត ដែលជាការពន្យល់អំពីច្បាប់ដែលមានស្រាប់ ឬដែលត្រូវបានប្រែក្លាយទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[66]។

៤២. សាលក្រមសាលាក្តីយោធាអន្តរជាតិ (សាលក្រមNuremberg) ដែលបានប្រកាសក្រោមការគាំទ្រពីធម្មនុញ្ញNuremberg បានលើកឡើងថាយោងតាមការទទួលខុសត្រូវបទឧក្រិដ្ឋចំពោះទង្វើដែលធ្វើឡើងដើម្បីអនុវត្តផែនការរួមមួយ ឬការសមគំនិតនៃមាត្រាទី៦ មិនបានបន្ថែមបទឧក្រិដ្ឋដោយឡែក ឬថ្មីទៅលើអ្វីដែលគេបានរៀបរាប់រួចមកហើយ ប៉ុន្តែអត្ថបទច្បាប់នេះត្រូវបានរៀបចំបង្កើតឱ្យមានការទទួលខុសត្រូវរបស់ជនណា ដែលបានចូលរួមក្នុងផែនការរួមមួយ[67]។ នៅក្នុងការវិភាគផែនការរួមដើម្បីរៀបចំ និងធ្វើសង្គ្រាម និងការលើកឡើងថាធម្មនុញ្ញ Nuremberg គ្រាន់តែកំណត់និយមន័យការសមគំនិតប្រព្រឹត្តអំពើសង្គ្រាមឈ្លានពាន ថាជាបទឧក្រិដ្ឋដោយឡែក សាលាក្តីយោធាអន្តរជាតិបានបញ្ជាក់ថា: "ទឡ្ហីករណ៍ដែលថាការរៀបចំផែនការរួម មិនអាចកើតឡើងពេលដែលមានភាពផ្តាច់ការ គឺមិនត្រឹមត្រូវ មិនសមហេតុផលទេ។ ផែនការអនុវត្តដែលមនុស្សមួយចំនួនចូលរួម ក៏នៅតែជាផែនការរួម ទោះបីជាមានតែមនុស្សម្នាក់ដឹងអំពីផែនការនេះក៏ដោយ។ ហើយជនទាំងឡាយណាដែលអនុវត្តផែនការនេះ មិនត្រូវគេចវេសពីការទទួលខុសត្រូវដោយនិយាយថា ពួកគេគ្រាន់តែធ្វើតាមបញ្ជាអ្នកដែលដឹងអំពីផែនការនេះតែប៉ុណ្ណោះនោះទេ។ Hitlerមិនអាចធ្វើសង្គ្រាមតែម្នាក់ឯងបានទេ។ គាត់ត្រូវមានការសហការណ៍ពីអ្នកធំ មេបញ្ជាការកងទ័ព អ្នកការទូត និងអ្នកជំនួញ។ ពេលពួកគេដឹងអំពីបំណងរបស់Hitler ហើយយល់ព្រមសហការណ៍ជាមួយHitlerបានសេចក្តីថា ពួកគេជាបក្សពួកក្នុងគម្រោងផែនការដែលHitler បានរៀបចំឡើង។ ពួកគេទាំងអស់នោះមិនត្រូវចាត់ទុកថាមិនបានដឹងអ្វី ឬគ្មានទោសនោះទេ ពីព្រោះHitler បានប្រើប្រាស់ពួកគេ ដូចនេះពួកគេប្រាកដជាបានដឹងអ្វីដែលពួកគេកំពុងធ្វើ។ ការពិតដែលថាពួកគេត្រូវបានមេដឹកនាំផ្តាច់ការជាអ្នកចាត់តាំងឱ្យទៅធ្វើកិច្ចការ មិនបានលើកលែងការទទួលខុសត្រូវចំពោះទង្វើពួកគេផ្ទាល់ឡើយ។ ទំនាក់ទំនងរវាងមេដឹកនាំ និងកូនចៅមិនអាចបង្ខាំងពួកគេពីការទទួលខុសត្រូវបានឡើយហើយវាមិន

66

67

ជាងគ្នាប៉ុន្មានទេ ក្នុងករណីកាប្រព្រឹត្តិបទឧក្រិដ្ឋក្នុងស្រុកដែលគេបានរៀបចំ[68]។ ច្បាប់យុត្តិសាស្ត្រក្រោយមកដែលដោះស្រាយឧក្រិដ្ឋកម្មសង្គ្រាម បានបញ្ជាក់ជាថ្មី ឬបង្កើតឱ្យមានគោលការណ៍ដែលមានសង្ខេបយ៉ាងច្បាស់នៅក្នុងលិខិតុបករណ៍មូលដ្ឋានគ្រឹះ រៀបរាប់លម្អិតពីខាងលើ និងនៅក្នុងសាលក្រមNuremberg។

## ១. ទម្រង់ទី១ "ទម្រង់មូលដ្ឋាន" នៃសហកម្មឧក្រិដ្ឋកម្មរួម : ច្បាប់យុត្តិសាស្ត្រ

៤៣. ករណីដែលជាឧទាហរណ៍នៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ "ទម្រង់មូលដ្ឋាន" ទាក់ទងនឹងកាលៈទេសៈដែលសមាជិកទាំងនៃសហកម្មឧក្រិដ្ឋកម្មរួម មានចេតនាឧក្រិដ្ឋដូចគ្នា និងដើរតួនាទីខុសៗគ្នា។ ឧទាហរណ៍ ក្នុងសំណុំរឿង Georg Otto Sandrock et al. ("Almelo Trial") ពួកមន្ត្រីថ្នាក់ទាបអាឡឺម៉ង់ត្រូវបានកាត់ទោសចំពោះការប្រហារជីវិតដោយគ្មានការកាត់សេចក្តីទៅលើអ្នកបើកយន្តហោះជនជាតិអង់គ្លេស និងជនស៊ីវិលហូឡង់មួយរូប[69]។ ក្នុងការប្រហារជីវិតនីមួយៗ ពួកអាឡឺម៉ង់បានដឹកពួកគេតាមរថយន្តទៅកន្លែងប្រហារជីវិត។ ម្នាក់ឈរក្បែរឡាន ម្នាក់ទៀតជាអ្នកបាញ់អ្នកបើកយន្តហោះ និងម្នាក់ទៀតដែលជាអ្នកបញ្ជាឱ្យប្រហារជីវិត ជាអ្នកជីករណ្តៅ[70]។ រដ្ឋអាជ្ញាយោធា (Judge Advocate) បានសន្និដ្ឋានករណីសម្លាប់អ្នកបើក យន្តហោះថា "គ្មានភស្តុតាងប្រកែកបានថាអ្នកទាំងបី (ជនជាប់ចោទ) មិនបានដឹងអំពីអ្វីដែលពួកគេកំពុងធ្វើនោះទេហើយពួកគេបានទៅកន្លែងប្រហារជីវិត ក្នុងគោលបំណង សម្លាប់អ្នកបើកយន្តហោះនោះតែម្តង។ ប្រសិនមនុស្សទាំងអស់មានវត្តមាន ក្នុងពេលតែមួយចូលរួមក្នុងក្រុមប្រព្រឹត្តបទល្មើសខុសច្បាប់ ដែលម្នាក់ៗជួយដល់ផែនការរួមតាមមធ្យោបាយរៀងៗខ្លួននោះ ពួកគេត្រូវជាប់ពិរុទ្ធស្មើៗគ្នាចំពោះមុខច្បាប់"[71]។

ជនជាប់ចោទទាំងអស់ ត្រូវបានរកឃើញថាមានទោសចំពោះការសម្លាប់ទាំងឡាយដែលពួកគេបានចូលរួមចំណែក[72]។ ការបែងចែកតួនាទីរបស់ជនជាប់ចោទក្នុងការសម្លាប់អ្នកបើកយន្តហោះត្រូវបានគេពន្យល់នៅក្នុងការកាត់សេចក្តី ដោយជនដែលបានបាញ់សម្លាប់អ្នកបើកយន្តហោះ

68
69
70
71
72

និងអ្នកដែលបញ្ជាឱ្យសម្លាប់ត្រូវបានកាត់ទោសប្រហារជីវិត រីឯបុរសដែលឈរនៅក្បែរឡាន ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ១៥ឆ្នាំ[73]។

៤៤. ស្រដៀងគ្នានេះដែរ រដ្ឋអាជ្ញាក្នុងសំណុំរឿងHolzer et al. ជនជាតិអាឡឺម៉ង់ ដែលត្រូវចោទពីបទសម្លាប់ឈ្លើយសឹកសញ្ជាតិកាណាដាម្នាក់ដោយគ្មានការកាត់ទោស បានសន្និដ្ឋានថា "ប្រសិនបើតុលាការរកឃើញថា ជនជាប់ចោទបានដឹងអំពីគោលបំណងសម្លាប់អ្នកបើកយន្តហោះដូច្នេះដូចតុលាការបានដឹងច្បាស់ហើយ គឺថាជនដែលចូលរួមក្នុងក្រុមប្រព្រឹត្តបទឧក្រិដ្ឋខុសច្បាប់ ហើយរួមចំណែកជួយសម្រេចផែនការតាមមធ្យោបាយរៀងៗខ្លួននោះ បានសេចក្តីថា ពួកគេមានពិរុទ្ធស្មើៗគ្នាចំពោះមុខច្បាប់"[74]។ រដ្ឋអាជ្ញាក្នុងសំណុំរឿង Franz Schonfeld និងសំណុំរឿង៩ ផ្សេងទៀត បានទាញពីវិធានមួយនៃច្បាប់សារធាតុដែលនិយាយថា "ប្រសិនបើជនមួយចំនួនចូលរួមផែនការខុសច្បាប់ណាមួយ ឬគោលបំណងត្រឹមត្រូវតាមច្បាប់ណាមួយ ដោយប្រើមធ្យោបាយខុសច្បាប់ ហើយក្នុងការអនុវត្តន៍ផែនការនោះ មានជនណាម្នាក់ ក្នុងចំណោមគ្នីគ្នាបានសម្លាប់មនុស្ស វាជាឃាតកម្មដែលប្រព្រឹត្តដោយមនុស្សដែលមានវត្តមាន មិនថាពួកគេគ្រាន់តែជួយ ឬសមគំនិតនោះទេ ឱ្យតែការស្លាប់នោះបង្កឡើងដោយសមាជិកណាម្នាក់ក្នុងបំណងសម្រេចផែនការរួម"[75]។

៤៥. ក្នុងសំណុំរឿង Feurstein និងសំណុំរឿងផ្សេងទៀត (សំណុំរឿង Ponzano) វិញ រដ្ឋអាជ្ញាតុលាការយោធាអង់គ្លេស បានពន្យល់ថា ការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋសម្លាប់មនុស្សមួយ មិនមែនបានសេចក្តីថាត្រឹមតែជាមូលហេតុផ្ទាល់នៃការស្លាប់ដោយការបង្ករបួសដល់ស្លាប់នោះទេ វាក៏មានន័យថាជាការចូលរួមមិនផ្ទាល់មួយផងទៀត"[76]។ រដ្ឋអាជ្ញាបានគូសបញ្ជាក់យ៉ាងល្អិតល្អន់យ៉ាងដូច្នេះថា: "ជនម្នាក់អាចជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយមិនចាំបាច់មានវត្តមាននៅទីកន្លែងកើតហេតុនោះទេ។ ជននោះបានចូលរួមក្នុងការរៀបចំឱ្យមានបទឧក្រិដ្ឋ។ និយាយម្យ៉ាងទៀត គឺជាស្ពឺក្នុងកង់នៃហេតុការណ៍ដែលនាំឱ្យមានឃាតកម្មនោះ។ ជននោះអាចជួយជ្រោមជ្រែងផែនការនោះដោយមិនគ្រាន់តែបញ្ជាឱ្យគេប្រព្រឹត្តបទឧក្រិដ្ឋ

73
74
75
76

ប៉ុណ្ណោះទេ ប៉ុន្តែជននោះគឺអាចថែមទាំងជួយជ្រោមជ្រែងផែនការតាមមធ្យោបាយជាច្រើនទៀតផង" [...][77]។

រដ្ឋអាជ្ញាបានទាត់ចោលរឿងវិវាទ ដែលជនជាប់ចោទអាចគេចផុតពីការទទួលខុសត្រូវដោយអះអាងថាបទល្មើសសម្លាប់មនុស្សនោះក៏នៅតែអាចកើតឡើងដែរ បើទោះបីជាគ្មានការចូលរួមពីពួកខ្លួនក៏ដោយ ដោយពន្យល់ថា ជនជាប់ចោទអាចជាប់ពិរុទ្ធដោយមិនចាំបាច់ជាខ្សែបណ្ដាញសំខាន់ក្នុងទំនាក់ទំនងហេតុនិងផលនោះទេ ឲ្យតែជនជាប់ចោទជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងបានដឹងអំពីពិរុទ្ធភាព នៃគោលបំណងឧក្រិដ្ឋកម្មនោះ"[78]។

៤៦. ក្នុងសំណុំរឿងEinsatzgruppen ភាគីដើមចោទ បានតវ៉ាទៅកាន់សាលាក្តីសហរដ្ឋអាមេរិកមួយថាជនជាប់ចោទថ្នាក់ទាបRadetzky និងSchubert ក្នុងចំណោមជនឯទៀត ជាប់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះពួកគេជាសមាជិកនៃអង្គភាពEinsatz ដោយក្រុមនេះមានបេសកកម្មច្បាស់លាស់មួយ ដែលសមាជិកគ្រប់គ្នាដឹងច្បាស់ ដើម្បីអនុវត្តកម្មវិធីសម្លាប់មនុស្សទ្រង់ទ្រាយធំមួយ ហើយសមាជិកដែលជួយឲ្យអង្គភាពនេះដំណើរការ ត្រូវជាប់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលអង្គភាពនេះប្រព្រឹត្ត[79]។ ខាងភាគីដើមចោទបានលើកទឡ្ហីករណ៍ថា មាត្រាII (២) នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ "មានភាពស្របគ្នាទៅនឹងគោលការណ៍ដែលគេទទួលស្គាល់សម្រាប់ប្រព័ន្ធច្បាប់រីកចម្រើន" ហើយប្រកាសថាជនណាដែលចូលរួមដោយស្ម័គ្រចិត្តក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬ "ក៏ជាប់ទាក់ទងនឹងផែនការ ឬក្រុមប្រព្រឹត្តបទល្មើស" ពាក់ព័ន្ធក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬជាមនុស្សរបស់អង្គការ ឬក្រុមមួយដែលចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ត្រូវជាប់ពិរុទ្ធទាំងអស់គ្នាជាមួយនឹង"ចារី"[80]។ យោបល់ និងសាលក្រមនៃសាលាក្តីនេះ បានរកឃើញថា Radetzky និងSchubert មានពិរុទ្ធចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះ Radetzky បានចូលរួមដោយស្ម័គ្រចិត្ត ក្នុងឧក្រិដ្ឋកម្មទាំងនេះ និងពីព្រោះតែការចូលរួមជារួមរបស់Schubert ក្នុងគម្រោងផែនការរបស់ Einsatzgruppe D"[81]។

77
78
79
80
81

**២. ទម្រង់ទី២ "ទម្រង់ជាប្រព័ន្ធ" នៃសហកម្មឧក្រិដ្ឋកម្មរួម: ច្បាប់យុត្តិសាស្ត្រ**

៤៧. ទម្រង់ទី២ ដែលក្លាយមកពីទម្រង់ទី១ ក្នុងបរិបទដែលអង្គភាពចាត់ចែងប្រមូលផ្តុំ ដែលជាករណីក្រុមទាំងនោះធ្វើសកម្មភាពអនុលោមទៅតាមផែនការរួមពិសេសមួយ ត្រូវបានលើកឧទាហរណ៍មកបញ្ជាក់ដោយសំណុំរឿង ជំរុំប្រមូលផ្តុំDachau[82] ជំរុំប្រមូលផ្តុំMauthausen[83] និងBelsen[84]។

៤៨. ក្នុងសំណុំរឿងBelsen រដ្ឋអាជ្ញាយោធាបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយទៅសំណុំរឿងសម្រាប់ភាគីដើមចោទផ្អែកលើ(១) ការដឹងរបស់បុគ្គលិកAuschwitz "ថាប្រព័ន្ធមួយ និងជាការដំណើរការធម្មតានៃការប្រព្រឹត្តិកំពុងដាក់ឲ្យប្រើប្រាស់" ដើម្បីធ្វើបាបអ្នកជាប់ឃុំឃាំង និង(២) ការចូលរួមរបស់បុគ្គលិក ក្នុងដំណើរការធម្មតានៃការប្រព្រឹត្តិ នៅក្នុងការជួយជ្រោមជ្រែងកិច្ចព្រមព្រៀងរួមក្នុងការរៀបចំបង្កើតជំរុំប្រមូលផ្តុំនោះដោយភាពសាហាវព្រៃផ្សៃ[85]។ ក្នុងសំណុំរឿងជំរុំប្រមូលផ្តុំ Dachau តុលាការរដ្ឋាភិបាលយោធាសហរដ្ឋអាមេរិក អះអាងថាសមាជិកបុគ្គលិកនៃជំរុំប្រមូលផ្តុំណាដែលបានចូលរួមយ៉ាងសកម្មក្នុងជំរុំនោះ ដែលពួកខ្លួនបានដឹងអំពីការកាប់សម្លាប់មនុស្ស និងភាពយង់ឃ្នង គឺជាការធ្វើសកម្មភាពអនុលោមទៅតាមការរៀបចំតាក់តែងរួមដើម្បីរំលោភច្បាប់ និងការប្រើប្រាស់សង្គ្រាម" និងជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម បើទោះបីជាវិសាលភាព និងសារជាតិនៃការចូលរួមរបស់ពួកគេ មានការខុសប្លែកពីគ្នាក៏ដោយ[86]។ កម្រិតខុសៗគ្នានៃការចូលរួមរបស់ជនជាប់ចោទ ត្រូវបានតុលាការយកមកពិចារណាក្នុងការកាត់ទោសពី៥ឆ្នាំក្នុងការពលកម្ម ដល់ការប្រហារជីវិត[87]។ ក្នុងសំណុំរឿងជំរុំប្រមូលផ្តុំ Mauthausen តុលាការរដ្ឋាភិបាលយោធាសហរដ្ឋអាមេរិក ស្រដៀងគ្នាបានរកឃើញជនជាប់ចោទ៦១នាក់ថាមានទោស ដោយសម្អាងថាអ្នកដែលនៅជំរុំប្រមូលផ្តុំ បានដឹងអំពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មសម្លាប់មនុស្សដែលគ្មានការទប់ស្កាត់ និងដឹងអំពីផែនការរបស់ពួកមន្ត្រីReich ក្នុងការសម្លាប់មនុស្ស[88]។ តុលាការបានសម្រេចថារាល់មន្ត្រី ឬបុគ្គលិក ដែលគ្រប់គ្រង ឬឃរជើង ឬចូលរួមក្នុងប្រតិបត្តិការរបស់ជំរុំនោះ ក្នុងមធ្យោបាយណាក៏ដោយ ក្នុងលក្ខណៈណាក៏ដោយ ត្រូវជាប់ពិរុទ្ធទាំងអស់[89]។

82
83
84
85
86
87
88
89

### ៣. ទម្រង់ទី៣ "ទម្រង់ទូលាយ" នៃសហកម្មឧក្រិដ្ឋកម្មរួមៈ ច្បាប់យុត្តិសាស្ត្រ

៤៩. គោលការណ៍នៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលឃើញ មិនស្ថិតនៅក្នុងការរៀបចំគាត់តែងរួមនោះ ត្រូវបានបង្ហាញដោយសំណុំរឿងជាច្រើន។ សំណុំរឿងThe Essen Lynching[90] គឺជាឧទាហរណ៍មួយដែលកើតចេញពីបរិបទនៃអំពើហិង្សាបង្កដោយហ្វូងមនុស្ស។ ជនជាប់ចោទសញ្ជាតិអាល្លឺម៉ង់ទាំង៧នាក់ក្នុងសំណុំរឿងនេះ ដែលមានដូចជាមេក្រុមកងទ័ព ពលទាហាន និងអ្នកស្រុកEssen ជនស៊ីវិលចំនួន៥នាក់ ត្រូវបានចោទពីបទប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមមួយ ដោយសារពួកគេ រួមជាមួយមនុស្សផ្សេងៗទៀត "មានជាប់ពាក់ព័ន្ធក្នុងការសម្លាប់" អ្នកបើកយន្តហោះសញ្ជាតិអង់គ្លេសចំនួន៣នាក់ ដែលជាឈ្លើយសឹក[91]។ ប្រធានក្រុមរូបនោះ បានបញ្ជាមនុស្ស២នាក់ មានទាំងពលទាហានម្នាក់ផង ឱ្យបណ្ដើរអ្នកបើកយន្តហោះទាំង៣នាក់នោះ ទៅកាន់អង្គភាពLuftwaffe ដែលនៅជិតបំផុត ដើម្បីសួរចម្លើយ។ នៅពេលបណ្ដើរនោះ ពួកគេបាននិយាយចោទប្រកាន់ខ្លាំងៗ ដើម្បីឱ្យហ្វូងមនុស្សអាចស្ដាប់ឮ ថាការបណ្ដើរនោះនឹងមិនមានបំណងរំខានដល់ហ្វូងមនុស្ស ប៉ុន្តែជាការដាក់ទោសដល់អ្នកទោស[92]។ ខណៈពេលអ្នកទោសត្រូវបានបណ្ដើរទៅកាន់ផ្លូវសំខាន់ៗEssen ហ្វូងមនុស្ស ចាប់ផ្ដើមវាយដំអ្នកទោស និងគប់ឈើ ដុំថ្មសំដៅពួកគេ[93]។ នាយទោសសញ្ជាតិអាល្លឺម៉ង់មិនស្គាល់ឈ្មោះម្នាក់បានបាញ់ប្រហារ និងបណ្ដាលឱ្យអ្នកបើកយន្តហោះមួយរូបរបួសក្បាល[94]។ ពេលពួកអ្នកបើកយន្តហោះទាំងបីនាក់ទៅដល់ស្ពានមួយ ពួកគេបានត្រូវរុញទម្លាក់តាមបង្កាន់ដៃបង្កឱ្យអ្នកបើកយន្តហោះម្នាក់ស្លាប់ដោយសារការធ្លាក់ និងដទៃទៀតស្លាប់ដោយសារការបាញ់ពីលើស្ពាន និងការវាយដំពីហ្វូងមនុស្ស[95]។

៥០. ភាគីដើមចោទបានលើកឡើងករណីថាគ្មានចេតនាសម្លាប់ ត្រូវតែបង្ហាញដើម្បីផ្ដន្ទាទោសការសម្លាប់មនុស្សដោយខុសច្បាប់ ដោយអាចជាមនុស្សឃាត ប៉ុន្តែមិនមែនជាឃាតកម្មនោះទេ[96]។ ភាគីដើមចោទបានលើកឡើងករណីថារាល់ជនដែលចាត់វិធានការណ៍ណាមួយ ដោយស្ម័គ្រចិត្ត

90
91
92
93
94
95
96

ប្រឆាំងនឹងអ្នកបើកបរយន្តហោះណាម្នាក់ក្នុងចំណោមអ្នកទាំង៣ "ត្រូវមានទោសត្រង់ថា ជននោះមានជាប់ពាក់ព័ន្ធនឹងការសម្លាប់" ដោយលើកហេតុផលថា"រាល់សមាជិកហ្វូងមនុស្សបានដឹងថាអ្នកបើកយន្តហោះ ត្រូវបានសម្លាប់ ហើយអ្នកនៅក្នុងហ្វូងមនុស្សដែលបានវាយដំពួកអ្នកបើកយន្តហោះម្នាក់មួយដៃមួយជើងនោះ គឺត្រូវទទួលខុសត្រូវទាំងផ្នែកស្មារតី និងផ្នែកឧក្រិដ្ឋកម្ម ចំពោះការស្លាប់របស់ពួកគេ"[97]។

៥១. គ្មានរដ្ឋអាជ្ញាយោធា (Judge Advocate) ណាត្រូវបានតែងតាំងនៅក្នុងសំណុំរឿងនេះទេ ហើយដូច្នេះក៏គ្មានទេការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយទៅលើសំណុំរឿងនេះនៅក្នុងតុលាការទេ[98]។ ទោះបីជាយ៉ាងដូច្នេះក្តី ការសន្និដ្ឋានអាចត្រូវបានទាញអំពីការលើកហេតុផលសម្អាងរបស់តុលាការ ពីសាលក្រម និងភស្តុតាងធ្វើសេចក្តីសង្ខេបដោយមេធាវី[99]។ ប្រធានក្រុមកងទ័ពរូបនោះត្រូវបានផ្តន្ទាទោស និងកាត់ទោសប្រហារជីវិតដោយព្យួរក ចំណែកឯពលទាហាននោះវិញដែលគេបញ្ជាឲ្យមិនធ្វើអន្តរាគមន៍ចំពោះការសម្លាប់អ្នកបើកយន្តហោះទាំង៣នាក់ ត្រូវជាប់ពន្ធនាគារ៥ឆ្នាំ[100]។ ក្នុងចំណោមជនស៊ីវិល៥រូប មានជនស៊ីវិល៣រូបត្រូវបានតុលាការរកឃើញថាមានទោស[101]។ ជនស៊ីវិលម្នាក់ដែលបានវាយដំទៅលើអ្នកបើកយន្តហោះនៅលើស្ពាន ហើយបន្ទាប់មកបានចុះទៅក្រោមស្ពានរួចគ្រវែងជនរងគ្រោះដែលគ្នានៅសល់ដង្ហើមចង្រិត ចូលទៅក្នុងជ្រោះនោះ ត្រូវបានតុលាការកាត់ទោសប្រហារជីវិតដោយព្យួរក[102]។ ជនស៊ីវិលម្នាក់ទៀតដែលសាក្សីបានឃើញថាគាត់បានវាយដំពួកអ្នកបើកយន្តហោះដែរ ហើយឃើញគាត់ព្យាយាមយកកាំភ្លើងទៅបាញ់អ្នកបើកយន្តហោះនៅក្រោមស្ពាន ហើយស្រែកថាពួកអ្នកបើកយន្តហោះគួរត្រូវតែសម្លាប់ចោលនោះ បានត្រូវតុលាការកាត់ទោសជាប់ពន្ធនាគារមួយជីវិត[103]។ ជនស៊ីវិលទី៣ ដែលគឺជាអ្នកសារភាពថាបានចូលដៃវាយដំពួកអ្នកបើកយន្តហោះនោះ ត្រូវបានផ្តន្ទាទោស និងកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន១០ឆ្នាំ[104]។

៥២. តុលាការសាលាឧទ្ធរណ៍ICTY លើកហេតុផលក្នុងរដ្ឋអាជ្ញាទល់នឹង Tadic ថាគេអាចទាញការសន្និដ្ឋានពីសាលក្រមក្នុងសំណុំរឿងEssen Lynching ថា ជនជាប់ចោទត្រូវបានរកឃើញថាមានទោស បើទោះបីជាពួកគេបានចូលរួមដោយមធ្យោបាយផ្សេងៗគ្នាក្នុងការសម្លាប់ក៏ដោយ

97
98
99
100
101
102
103
104

ហើយបើទោះបីជាពួកគេទាំងអស់គ្នាគ្មានចេតនាសម្លាប់មនុស្សក៏ដោយ។ ប៉ុន្តែពួកគេខ្លះគ្រាន់តែមានចេតនាធ្វើបាបអ្នកទោសតែប៉ុណ្ណោះ[105]។ សាលាឧទ្ធរណ៍បានទាញការសន្និដ្ឋានស្រដៀងគ្នានេះ ពីលទ្ធផលនៃសំណុំរឿងBorkum Island ដែលជាសំណុំរឿងប្រហារជីវិតឈ្លើយសឹក ដែលមាននិយាយលម្អិតនៅក្នុងរដ្ឋអាជ្ញាទល់នឹង Tadic[106]។

៥៣. ឧទាហរណ៍បន្ថែមទៀត គឺសំណុំរឿងមួយចំនួនដែលតុលាការអ៊ីតាលីក្រោយសង្គ្រាមលោកលើកទី២ ជាអ្នកសម្រេច ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងឈ្លើយសឹក កសិករអ៊ីតាលី ឬសមាជិកនៃកងទ័ពអ៊ីតាលី ប្រយុទ្ធប្រឆាំងនឹងពួកអាឡឺម៉ង់ និង Repubblica Sociale Italiana (RSI) រដ្ឋាភិបាលស្រមោលក្រោមការគ្រប់គ្រងរបស់អាឡឺម៉ង់ បង្កើតឡើងដោយមេដឹកនាំហ្វាស៊ីស។ សំណុំរឿងអ៊ីតាលីនេះ គឺកំពុងបំភ្លឺចំណុចនេះយ៉ាងច្បាស់ ពីព្រោះអ៊ីតាលីជាគំរូជាក់ស្តែងនៃប្រព័ន្ធមួយដែលយកតាមគំរូសហចារីរួម ដែលជាវិធីសាស្ត្ររបស់ធម្មនុញ្ញNuremberg[107]។

៥៤. ក្នុងD"Ottavio និង Others Court of Cassation នៃប្រទេសអ៊ីតាលីបានពិចារណាសំណុំរឿងអ្នកភូមិ៤នាក់ ដែលបានឡោមព័ទ្ធពួកឈ្លើយសឹកនៅតំបន់ទឹកផុសមួយ ក្នុងអំឡុងពេលមានអ្នកភូមិម្នាក់ បានបាញ់ប្រហារអ្នករត់គេចខ្លួនម្នាក់ឈ្មោះVusovic ដែលក្រោយមកបានបាត់បង់ជីវិត[108]។ ក្នុងការផ្តន្ទាទោសអ្នកភូមិទាំង៣ ដែលមិនមែនជាអ្នកដែលបានបាញ់ប្រហារមនុស្សនោះ Teramo Court of Assize បានអនុវត្តមាត្រា១១៦ នៃក្រមព្រហ្មទណ្ឌអ៊ីតាលីដែលបានចែងថា "ពេលបទឧក្រិដ្ឋខុសគ្នាពីបទឧក្រិដ្ឋប្រព្រឹត្តដោយឆន្ទៈរបស់អ្នកចូលរួមណាម្នាក់ក្នុងចំណោមពួកគេហើយខុសពីឧក្រិដ្ឋកម្ម ដែលអ្នកចូលរួមនោះព្រមទទួលការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ប្រសិនបើអង្គហេតុគឺជាផលវិបាកនៃសកម្មភាពរបស់គាត់ ឬការមិនបានប្រព្រឹត្តរបស់គាត់[109]"។

៥៥. អ្នកភូមិទាំង៣នាក់ ដែលមិនបានបាញ់ប្រហារមនុស្សនោះ បានដាក់ពាក្យប្តឹងឧទ្ធរណ៍ ដោយលើកហេតុផលថាពួកខ្លួនគ្រាន់តែមានចេតនាចាប់ខ្លួនVisovic ប៉ុណ្ណោះ អញ្ចឹងពួកខ្លួនគួរត្រឹមតែទទួលខុសត្រូវចំពោះការប៉ុនប៉ងឃុំមនុស្សខុសច្បាប់ គឺល្មមហើយ[110]។ តុលាការ The Court of Cassation បានទទួលស្គាល់ការដាក់កំហិតឲ្យជនជាប់ចោទទទួលខុសត្រូវរបស់តុលាការដំបូង ដោយពន្យល់មូលហេតុថា ដើម្បីឲ្យអ្នកចូលដៃម្នាក់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែល

105
106
107
108
109
110

មិនបានគ្រោងទុក នោះគេត្រូវតែមានភស្តុតាងនៃទំនាក់ទំនងហេតុនិងផល ដែលមិនគ្រាន់តែជាលក្ខណៈអត្តនោម័តិប៉ុណ្ណោះទេ តែត្រូវមានលក្ខណៈចិត្តសាស្ត្រទៀតផង រវាងអង្គហេតុដែលបានប្រព្រឹត្ត និងអង្គហេតុដែលបណ្តាលឲ្យមានចេតនាចង់ប្រព្រឹត្ត ដោយអ្នកចូលរួមទាំងអស់គ្នា និងអង្គហេតុមួយផ្សេងទៀត របស់អ្នកចូលរួមម្នាក់ក្នុងចំណោមគ្នីគ្នាទាំងអស់[111]។ ការទទួលខុសត្រូវដែលអាចកើតឡើងជាបន្តបន្ទាប់ត្រូវផ្អែកលើ "គោលការណ៍មូលដ្ឋានគ្រឹះនៃការយល់ស្របគ្នាអំពីបច្ច័យមិនអាស្រ័យគ្នាទៅវិញទៅមក" ដែលអ្នកចូលរួមបានសារភាពចំពោះអំពើឧក្រិដ្ឋ ទាំងក្នុងពេលពួកគេជាប្រភពផ្ទាល់នៃឧក្រិដ្ឋកម្ម និងក្នុងពេលពួកគេជាប្រភពមិនផ្ទាល់នៃឧក្រិដ្ឋកម្ម យោងទៅតាមក្បួនច្បាប់ causa sausae est causa causasti [បច្ច័យនៃទង្វើក៏ជាច្ច័យនៃផលដែរ គឺថា នរណាម្នាក់ស្ម័គ្រចិត្តបង្កើតស្ថានការណ៍មួយដែលនាំទៅដល់ ឬកើតចេញជាអំពើឧក្រិដ្ឋ អ្នកនោះត្រូវទទួលខុសត្រូវចំពោះទង្វើនោះ ទោះបីជាខ្លួនមាន ឬគ្មានឆន្ទៈប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនោះក៏ដោយ]។

៥៦. តុលាការThe Court of Cassation បានលើកសំអាងហេតុថា ហេតុនិងផលដែលមានលក្ខណៈអត្តនោម័តិ គឺផ្អែកទៅលើអង្គហេតុដែលថាអ្នកចូលរួមទាំងអស់ បានសហការណ៍ផ្ទាល់ក្នុងឧក្រិដ្ឋកម្មនៃការប៉ុនប៉ងឃុំឃាំងមនុស្សដោយខុសច្បាប់ ដែលជាប្រភពមិនផ្ទាល់នៃហេតុការណ៍បាញ់ប្រហារ បន្តបន្ទាប់មកទៀត[112]។ "ហេតុនិងផលផ្អែកផ្លូវចិត្ត គឺសម្អាងទៅលើឆន្ទៈរួមក្នុងការចូលរួមប៉ុនប៉ងឃុំខ្លួនមនុស្សដោយខុសច្បាប់ ខណៈពេលដែលអាចប្រមើលឃើញការកើតឡើងនូវឧក្រិដ្ឋកម្មមួយផ្សេងទៀត ក្នុងកិច្ចដំណើរការចាប់ខ្លួនមនុស្ស ដូចដែលគេអាចសន្និដ្ឋានបានតាមរយៈការប្រើប្រាស់អាវុធ[113]។

៥៧. ផ្ទុយមកវិញ ក្នុងបរិបទនៃការកំណត់ថា មនុស្សណាម្នាក់មិនអាចទទួលការលើកលែងទោសបានដោយសារបានប្រព្រឹត្តឃាតកម្មដោយចេតនានោះ តុលាការអ៊ីតាលី The Court of Cassation បានសម្រេចជាច្រើនដងថា អ្នកចូលរួមក្នុងការកៀងគរកសិករទុកមួយកន្លែងដែលក្នុងនោះមានកសិករខ្លះត្រូវបានសម្លាប់ គឺមិនត្រូវទទួលខុសត្រូវចំពោះបទឃាតកម្មនោះទេ[114]។ ដូចក្នុងសំណុំរឿងAratano and Others and Berardi ជាដើម សនិទានភាពគឺសម្អាងទៅលើការខ្វះចេតនាប្រព្រឹត្តឃាតកម្ម[115] ខណៈពេលសនិទានភាពក្នុងសំណុំរឿងTossani គឺជាការខ្វះ

111
112
113
114
115

ការប្រមើលឃើញថា ការស្លាប់អាចកើតឡើងពីកាលៈទេសៈពិសេស និងមិនអាចដឹងមុន ដោយសារជនរងគ្រោះព្យាយាមគេចពីការចាប់ខ្លួន ហើយរត់ចេញតាមដំបូលផ្ទះ[116]។

៥៨. សំណុំរឿងទាំងអស់នេះមានចេទនាឱ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលឃើញ និងដែលត្រូវបានប្រព្រឹត្តដោយសមាជិកម្នាក់ផ្សេងក្នុងក្រុម ដែលមិនបានគ្រោងផែនការឧក្រិដ្ឋកម្ម បើទោះបីជាក្នុងសំណុំរឿងខ្លះ បុរេលក្ខខណ្ឌនៃចេទនាឧក្រិដ្ឋឱ្យទទួលខុសត្រូវ គឺមិនមានភាពច្បាស់លាស់ ឬដូចគ្នាទាំងអស់នៅទេ[117]។ សាលក្រមមួយទៀតរបស់តុលាការអ៊ីតាលី Court of Cassation ក្នុងពេលជាមួយគ្នានោះ ដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌនិយ័តមួយ ប៉ុន្តែមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាមទេ គឺជាសាលក្រមជួយពន្យល់អំពីលក្ខខណ្ឌចាំបាច់នៃទំនាក់ទំនងហេតុនិងផល។ ឧក្រិដ្ឋកម្មដែលអាចប្រមើលឃើញ ហួសពីផែនការរួម វាត្រូវជាឧក្រិដ្ឋកម្ម "ដែលមានការវិវត្តន៍មួយដែលសមហេតុផល និងអាចដឹងទុកជាមុន" នៃបទល្មើសដោយចេតនា ដែលមិនមែនជា "អង្គហេតុថ្មី" រួមមួយដែលមានស្វ័យភាពរបស់វា ដែលជាប់ពាក់ព័ន្ធនឹងអង្គហេតុ ដែលជាផលទទួលរបស់ដែលអ្នកប្រព្រឹត្ត ដោយទំនាក់ទំនងចៃដន្យនោះទេ"[118]។ តុលាការអ៊ីតាលី Court of Cassation បានពន្យល់នៅក្នុងសំណុំរឿង Mannelli and Others ថា "ពាក្យបច្ច័យ មិនថាជាបច្ច័យភ្លាមឬមិនភ្លាម ផ្ទាល់ឬប្រយោល ស្របពេលឬមិនស្របពេល មិនគួរច្រឡំជាមួយពាក្យថាឱកាសនោះទេ"[119]។

៥៩. ហេតុដូច្នេះ គោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម និងការការពារតទល់នឹងការជ្រុលហួសព្រំដែន បានចាក់គ្រឹះយ៉ាងរឹងមាំក្នុងយុត្តិសាស្ត្រមុនឆ្នាំ១៩៧៥។ យុត្តិសាស្ត្រនេះត្រូវបាន កំណត់ដោយអង្គជំនុំជម្រះកំពូល (Appeals Chamber) តុលាការ ICTY ដើម្បី "បង្កើតឱ្យបានរឹងមាំ នូវទស្សនាទានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។

៦០. ក្នុងនោះ មានបន្ថែមទៀតថា ចំពោះករណីខ្លះ ដែលបានយកមកជំនុំជម្រះនៅតុលាការអាល្លឺម៉ង់បន្ទាប់ពីសង្គ្រាមលោកលើកទី២ អនុលោមទៅតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យមាត្រា១០ ហាក់ដូចជា បញ្ជាក់ពីវិធីសាស្ត្រ ដែលយកមកប្រើប្រាស់ក្នុងករណីនានា ដូចលើកឡើងខាងលើ បើនិយាយជាទូទៅ បើទោះជាតុលាការទាំងនេះបានអនុវត្តច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យមាត្រា១០ ទាក់ទងនឹងខ្លឹមសារនៃឧក្រិដ្ឋកម្មទាំងនោះ ហើយដោយហេតុថា ចំពោះទម្រង់នៃការទទួល

116
117
118
119

ខុសត្រូវនេះក៏ដោយ ក៏ពួកគេពេញ ចិត្តអនុវត្តជាងនូវសញ្ញាណទូទៅនៃច្បាប់ព្រហ្មទណ្ឌអាល្លឺម៉ង់ ស្តីពីបទល្មើសសហចារី(*Mittaterschaft*) និង ការជួយទំនុកបម្រុង (*Beihilfe*) ដែរ។ ករណី Sch. និងករណីផ្សេងៗទៀត គឺជាការចង្អុល បង្ហាញជាក់ស្តែងនៃនិន្នាការនេះ ។

៦១. នៅរាត្រីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៣៨ ចុងចោទ និងអ្នកដទៃទៀត (សមាជិកក្រុមអេសអេស) ទៅរកអិនដល់កន្លែងរបស់គាត់ ដោយបានឆែកឆេរផ្ទះគាត់ យករូបគាត់ទៅកាន់ស្ថានីយប៉ូលីស និង យកទៅព្រះវិហារហ្សីហ្វកំពុងឆេះសន្ធោសន្ធៅមួយ ដែលនៅទីកន្លែងហ្នឹង គាត់ត្រូវបាន អ្នកដទៃទៀត ធ្វើបាបយ៉ាងឃោរឃៅ។ ចុងចោទបានយកអិនត្រឡប់ទៅស្ថានីយប៉ូលីសវិញ ហើយនៅតាមផ្លូវ អិន ត្រូវបានគតិយជន ដែលមិនអាចកំណត់អត្តសញ្ញាណបាញ់។ ខណៈកំពុង ដេកដួលលើក្តាក្រាល អិន ត្រូវបានមនុស្សមួយចំនួនក្នុងហ្វូងមនុស្សទាត់ធាក់ (គ្មានភស្តុតាង ណាមួយបង្ហាញថា ចុងចោទក៏បាន ទាត់ធាក់អិនផងដែរទេ)។ បន្ទាប់មកទៀត អិនក៏បាន បាត់បង់ជីវិត។ តុលាការ (*Oberldandesgericht* ឬ តុលាការឧទ្ធរណ៍) បានសម្រេចថា ឧប្បត្តិហេតុទាំងមូលនេះក្លាយទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយដោយចុងចោទបានរួម ចំណែកក្នុងឧក្រិដ្ឋកម្មនេះជាមួយដោយអំពើផ្ទាល់ខ្លួនដែរនោះ គាត់ត្រូវទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មនេះ។ ពាក់ព័ន្ធនឹងការប្រព្រឹត្តិអមនុស្សធម៌ដំបូងមកលើអិននៅមុខ ព្រះវិហារហ្សីហ្វ តុលាការបានអះអាងថា ប្រសិនបើចុងចោទបានដឹង ឬរំពឹងថា ដោយយកអិនទៅ ព្រះវិហារនោះ អិននឹងមានគ្រោះថ្នាក់ដោយហ្វូងមនុស្សធ្វើបាប ចុងចោទត្រូវទទួលខុសត្រូវចំពោះអំពើទាំងឡាយ ដែលបានប្រព្រឹត្តមកលើអិន។ ពាក់ព័ន្ធនឹងការទាត់ធាក់អិនពីសំណាក់ហ្វូងមនុស្ស តុលាការបាន អះអាងថា ចុងចោទចង់ធ្វើបាបអិន ហើយក្នុងខណៈដែលបុគ្គលមានសមត្ថកិច្ចធ្វើជាអ្នកឈរ មើល និងឲ្យដៃដល់ហ្វូងមនុស្ស ដូច្នេះហើយគាត់ក៏បានចូលរួមយ៉ាងសកម្មដែរចំពោះឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិនេះ ។

៦២. ដូច្នេះ វាហាក់ដូចជា តុលាការបានអនុវត្តគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ចំពោះ ឧបកថាដំបូងគេ (ការប្រព្រឹត្តអមនុស្សធម៌នៅមុខព្រះវិហារ) ខណៈដែលឧបកថានេះបាន រាប់បញ្ចូលទាំងគោលការណ៍នៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ចំពោះឧបកថាទីពីរ (ទាត់ធាក់ ដោយហ្វូងមនុស្ស)។

**ខ. ឫសគល់គោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមក្នុងប្រព័ន្ធជាតិសំខាន់ៗ**

៦៣. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលវិវត្តជាបន្តបន្ទាប់ក្នុងទសវត្សរ៍៤០ និង៥០ ក៏ត្រូវបានគេយកមកសំអាង ហើយភាគច្រើនមានឫសគល់ ឬខ្លឹមកពីហ្នឹង ហើយស្រដៀងគ្នានឹងបទប្បញ្ញត្តិជាតិឬ ច្បាប់ យុត្តិសាស្ត្រជាតិដែរ។ បើនិយាយជាទូទៅ ច្បាប់ជាតិ និងច្បាប់យុត្តិសាស្ត្រជាតិបានឆ្លុះបញ្ចាំងពីគោលការណ៍នៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី៣។ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី២ ដែលពាក់ព័ន្ធនឹងការប្រមូលផ្តុំ ការឃុំឃាំង ឬជំរុំឃុំឃាំង ជាទូទៅមិនមានលើកឡើងច្បាស់លាស់ទេនៅក្នុងប្រព័ន្ធច្បាប់ជាតិ ។

៦៤. ដើម្បីសង្ខេប ទ្រឹស្តីផ្សេងៗក្នុងប្រទេសប្រើប្រាស់ប្រព័ន្ធច្បាប់Common Law ដូចជាចក្រភពអង់គ្លេស ប្រកាន់យកទ្រឹស្តី "សហកម្មខុសច្បាប់រួម" និង "ការទទួលខុសត្រូវសហកម្មរួម" ដែលភាគច្រើន រាប់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី៣។ នៅសហរដ្ឋអាមេរិក ទ្រឹស្តីនៃ "ការសមគំនិត" និងការឃុបឃិតទំនងជារាប់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ហើយករណីផ្សេងៗទៀត ក្រៅពីករណី *"Pinkerton"* ដែលទទួលការរិះគន់ច្រើននោះ គឺរាប់បញ្ចូលក្នុងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ។ ប្រទេសផ្សេងៗទៀតរួមមាន៖ កាណាដា អូស្ត្រាលី និងហ្សំប៊ី ដែលប្រើប្រាស់ប្រព័ន្ធច្បាប់ Common Law ហើយដែលប្រកាន់យកគោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនោះមានឈ្មោះ ឬ អត្ថន័យជាផ្លូវការអ្វីក៏ដោយ។

៦៥. ប្រទេស ដែលប្រើប្រាស់ប្រព័ន្ធច្បាប់ Civil Law ដូចជាប្រទេសបារាំង អ៊ីតាលី កូរ៉េ ស្វីស និងអតីតសាធារណរដ្ឋ សហព័ន្ធ សង្គមនិយមយូហ្គូស្លាវី ប្រកាន់យកគោលការណ៍ ដែលស្របគ្នានឹង ឬដូចគ្នានឹងទ្រឹស្តីនេះ។ ប្រទេសទាំងនេះទំនងប្រើប្រាស់ចំណងជើងថា "ការរួមដៃប្រព្រឹត្តឧក្រិដ្ឋកម្ម" ឬ "ការសមគំនិត"។ នៅបារាំង គេប្រើពាក្យ *"association de malfaiteurs* និង *complicité"* ឯនៅ អ៊ីតាលី គេប្រើពាក្យ *"associazione per delinquere,* ឬ *concorso in attività criminose"* និង *"responsabilité des coauteurs, responsabilité des complices"* នៅប្រទេសផ្សេងៗទៀតដូចជា បែលហ្ស៊ិក ស្វីស និង អាល្លឺម៉ង់។ ទម្រង់នៃការទទួលខុសត្រូវទាំងនេះគ្របដណ្តប់លើស្ថានភាព សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី៣ ។

៦៦. ខណៈដែលយុត្តាធិការប្រើប្រាស់ច្បាប់ Civil Law ខ្លះ ដូចជាប្រទេសអាល្លឺម៉ង់ មិនមានចែងអំពីការទទួលខុសត្រូវ ជាប់ពាក់ព័ន្ធនឹងគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ឡើយ ហើយ

ប្រទេសផ្សេងៗទៀត មានទ្រឹស្តីជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ដែលចែងអំពីការទទួលខុសត្រូវដោយផ្អែកទៅលើចេទនានៃការធ្វើមិនដឹងមិនឮ (*dolus eventtualis)*។ ការបំភ្លឺយ៉ាងច្បាស់លាស់គឺមាននៅក្នុងសាលក្រម ដែលបានចេញដោយតុលាការបារាំង *Cour de cassation* ក៏ដូចជាតុលាការស្វីស *Tribunal Fédéral* ដោយគូសបញ្ជាក់ថា ជនសមគំនិតអាចនឹងទទួលខុសត្រូវចំពោះបទល្មើសឧក្រិដ្ឋ ដែលបានអនុវត្តដោយចារីដែលផងដែរ នៅពេលដែលជនសមគំនិតនោះបានបណ្តែតបណ្តោយខ្លួនរបស់គាត់ធ្វើមិនដឹងមិនឮចំពោះហេតុការដែលបានកើតឡើង។

៦៧. គួរតែមានការបំភ្លឺថា សញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួម ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិបម្រើគោលបំណងជាក់លាក់បង្ហាញតថភាពនៃឧក្រិដ្ឋកម្មរួមដែលមានលក្ខណៈសាំញ៉ាំ ដោយមិនយកតាមលំនាំជាតិមួយនេះ ឬមួយនៅឡើយ។ វាមិនចាំបាច់ទេចំពោះករណីដែលថា នៅក្នុងគ្រប់ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ មនុស្សត្រូវបានផ្តន្ទាទោសដោយសំអាងទៅលើសញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួម ឬសញ្ញាណប្រហាក់ប្រហែលគ្នានេះផ្សេងៗទៀត។ អ្វីដែលសំខាន់ (និងអ្វីដែលទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមព្យាយាមសម្រេចឲ្យបាន) នោះគឺធ្វើអ្វីដែលប្រព័ន្ធថ្នាក់ជាតិជាច្រើនត្រូវបានបង្កើតឡើងដោយរបៀបខុសៗគ្នា ពោលគឺ ដើម្បីឲ្យសាមីជនម្នាក់ៗ ចូលរួមក្នុងផែនការឧក្រិដ្ឋកម្មរួមទទួលខុសត្រូវចំពោះរាល់បទល្មើស ដែលខ្លួនបានរួមចំណែកអនុវត្ត។ នេះអាចមានន័យថា បុគ្គលម្នាក់គួរទទួលខុសត្រូវចំពោះរាល់ឧក្រិដ្ឋកម្ម ដែលជាលទ្ធផលជាក់ច្បាស់នៃការអនុវត្តគោលបំណងឧក្រិដ្ឋកម្មរួមនោះ បើទោះជាមិនបានចែងច្បាស់ក្នុងកិច្ចព្រមព្រៀង ឬគោលបំណងរួមណាមួយក្នុងចំណោមអ្នកចូលរួមក៏ដោយ។ បាតុភូតនេះអាចត្រូវបានហៅឈ្មោះដោយរបៀបខុសៗគ្នាក្នុងប្រព័ន្ធខុសៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ សនិទាននៃទ្រឹស្តីនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើន។ បន្ថែមលើនេះទៀត បើទោះជា ប្រទេសខ្លះមិនទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ឬទ្រឹស្តីស្រដៀងគ្នានេះក៏ដោយ ប្រទេសទាំងនោះអាចប្រើប្រាស់អត្ថន័យទូទៅនៃប្រព័ន្ធព្រហ្មទណ្ឌជាតិ។ ជាក់ស្តែង ប្រព័ន្ធទាំងនេះមានចំណាត់ការរង *ដាច់ដោយឡែក* ចំពោះឧក្រិដ្ឋកម្មរួម ដែលមានលក្ខណៈធ្ងន់ធ្ងរខ្លាំងឡើយ ពោលគឺប្រព័ន្ធទាំងនេះមានចំណាត់ការលើបទល្មើសឧក្រិដ្ឋកម្ម និងក្នុងករណីភាគច្រើន ច្បាប់ព្រហ្មទណ្ឌត្រូវតែយកមកប្រើប្រាស់សម្រាប់បទល្មើស ដែលមិនសូវមានលក្ខណៈធ្ងន់ធ្ងរ។ ទោះជាយ៉ាងនេះក្តី ដោយទទួលស្គាល់ថាអាចមានមូលហេតុមួយចំនួននៅថ្នាក់ជាតិ ក្នុងការដាក់កម្រិតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានបានឯកភាពគ្នាថានឹងប្រព្រឹត្តក៏ដោយ ក៏មូលហេតុទាំងនោះហាក់ដូចជាមិនស្របជា

មួយច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេ។ នៅពេលបុគ្គលម្នាក់ពិនិត្យមើលផ្នែកនេះនៃច្បាប់ បុគ្គលរូបនោះត្រូវពិចារណាអង្គហេតុមួយ ពោលគឺ នៅពេលមនុស្សមួយហ្វូងសម្រេចចូលរួមក្នុងអំពើឃោរឃៅមួយចំនួន (និងមិនចូលរួមក្នុងអំពើឃោរឃៅផ្សេងទៀត) មនុស្សទាំងអស់ត្រូវតែទទួលខុសត្រូវចំពោះហានិភ័យ ហើយមិនអាចធ្វើព្រងើយកណ្តើយចំពោះផលប៉ះពាល់ដ៏កំណាចដែលអាចកើតឡើងចេញពីគោលបំណងឧក្រិដ្ឋកម្មរួមរបស់ពួកគេឡើយ។ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមបង្កើតឡើង ដើម្បីធ្វើឱ្យជនសម្រេចបង្ក "ឧក្រិដ្ឋកម្មធំធេង" ទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនឱ្យបានជាអតិបរមា។ បន្ថែមលើនេះទៀត បទប្បញ្ញត្តិនេះគួរមានអានុភាពទប់ស្កាត់មួយដើម្បីប្រឆាំងមិនឱ្យមានការចូលរួមក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ រាល់ការបង្កើតឱ្យមានស្ថានភាពហានិភ័យមួយ ដែលអាចនាំទៅរកការចូលរួមក្នុងបទល្មើសបន្ថែមទៀត ត្រូវតែតម្រូវឱ្យមានការផ្តន្ទាទោស។ គេពុំចាំបាច់ពិចារណាអ្វីវែងឆ្ងាយទេថា អ្នកដែលបានព្រមព្រៀងចូលរួមដោយចេតនា ក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ត្រូវតែគិតអំពីសក្តានុពលនៃអំពើឃោរឃៅផ្សេងៗទៀត ដែលសមាជិកក្នុងក្រុមនេះអាចនឹងប្រព្រឹត្ត។

៦៨. ដើម្បីធ្វើសេចក្តីសន្និដ្ឋានលើចំនុចនេះ គោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមមានមូលដ្ឋានគ្រឹះលើ (i) ច្បាប់ជាតិ និងច្បាប់យុត្តិសាស្ត្រនៃប្រព័ន្ធច្បាប់ចម្បងៗរបស់ពិភពលោក និង (ii) សេចក្តីសម្រេច និងលិខិតុបករណ៍ ក្នុងប្រព័ន្ធតុលាការអន្តរជាតិ ។

## III. អង្គជំនុំជម្រះអាច និងគួរអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿងសមស្របនានា

៦៩. មាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងអំពីទម្រង់នៃការទទួលខុសត្រូវ ត្រូវបានយកគំរូតាមមាត្រា៧ នៃលក្ខន្តិកៈតុលាការ ICTY ។ ស្រដៀងគ្នានឹងលក្ខន្តិកៈនៃតុលាការ ICTY តុលាការ ICTR និងតុលាការពិសេស SCSL ដែរ មាត្រា២៩ នៃច្បាប់អ.វ.ត.កកំណត់អំពីការទទួលខុសត្រូវ ព្រហ្មទណ្ឌសម្រាប់ជន "ដែលបានរៀបចំផែនការ ញុះញង់ បញ្ជា ជួយទំនុកបម្រុង និងប្រព្រឹត្ត" អំពើ ឧក្រិដ្ឋកម្ម ដែលអាចត្រូវបានផ្តន្ទាទោសដោយតុលាការ។ ដូច តុលាការ ICTY តុលាការ ICTR និង តុលាការពិសេស SCSL បានបកស្រាយថា "ប្រព្រឹត្ត" គឺរាប់បញ្ចូលទាំងការចូលរួមក្នុងសហកម្ម ឧក្រិដ្ឋកម្មរួមមួយ ដូច្នេះអង្គជំនុំជម្រះក៏អាចបកស្រាយថា "ប្រព្រឹត្ត" គឺរាប់បញ្ចូលទាំងការទទួល ខុសត្រូវចំពោះការប្រព្រឹត្ត តាមរយៈសហកម្មឧក្រិដ្ឋកម្មរួមមួយបានដែរ ។

៧០. ដូចពិភាក្សាខាងក្រោម អ.វ.ត.ក អាចអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមឱ្យស្របគ្នាទៅនឹងគោលការណ៍គ្មានច្បាប់គឺគ្មានទោស *(mullum crimen sine lege)*។ បន្ថែមលើនេះទៀត ការអនុវត្តនូវការទទួលខុសត្រូវ សហកម្មឧក្រិដ្ឋកម្មរួមនឹងបម្រើដល់ផលប្រយោជន៍សំខាន់ៗចំនួនបី (១) ការទទួលខុសត្រូវដ៏ត្រឹមត្រូវ ចំពោះភាពធ្ងន់ធ្ងរទាំងស្រុងនៃឧក្រិដ្ឋកម្ម (២) ភាពស្របគ្នាតាមខ្សែបណ្តោយនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បើធៀបទៅនឹងអ្វីៗដែលធ្លាប់មានពីមុនក្រោយសង្គ្រាមលោកលើកទី២ ដូចបាន ពិភាក្សាមុននេះ និង (៣) ភាពស្របគ្នាតាមខ្សែបញ្ឈរនៅទូទាំងលំដាប់ថ្នាក់នៃតុលាការអន្តរជាតិ និងតុលាការកូនកាត់សហសម័យនេះ ដែលអនុវត្តការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ពោលគឺរាប់ចាប់តាំងពីតុលាការ ICTY ដល់តុលាការ ICTR ដល់តុលាការពិសេស SCSL ដល់ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត ក៏ដូច ជារហូតដល់តុលាការជាន់ខ្ពស់អ៊ីរ៉ាក់ (ករណី លើកលែងគឺមានតែតុលាការ ICC តែមួយគត់ ដែលផ្អែកទៅលើសន្ធិសញ្ញា ហើយដែលកន្លងមក ចៅក្រមរបស់តុលាការនេះបានសម្រេចផ្តល់នូវទម្ងន់តិចតួច ដល់ច្បាប់ទំនៀមទម្លាប់)។

**គ. ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមគឺស្របគ្នានឹងគោលការណ៍ គ្មានច្បាប់គឺគ្មានទោស**

(Nullum Crimen Sine Lege)

៧១. គោលការណ៍*គ្មានច្បាប់គឺគ្មានទោស*ទាមទារនូវបញ្ញាយុត្តិធម៌ ដែលការផ្តន្ទាទោសព្រហ្មទណ្ឌមួយគឺធ្វើឡើងដោយផ្អែកទៅលើការបំពានបទដ្ឋានមួយ ក្នុងអត្ថិភាពនៅពេលប្រព្រឹត្តអំពើរបស់ជនជាប់ចោទ ឬការខកខាន។ គោលការណ៍នេះបង្ការមិនឱ្យតុលាការណាមួយបង្កើតនូវច្បាប់ថ្មី ឬបកស្រាយច្បាប់ ដែលមានស្រាប់ណាមួយឱ្យលើសពីព្រំដែនសមស្របនៃការស្រាយបំភ្លឺ ដែលអាចទទួលយកបាន ពោលគឺមិនធ្វើឱ្យខកខានដល់ការវិវឌ្ឍរីកចំរើននៃច្បាប់ ឬការបកស្រាយច្បាប់ និងការស្រាយបំភ្លឺនូវធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយដោយតុលាការ។ បន្ថែមលើនេះទៀត មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋពិពណ៌នាពីបទដ្ឋាន ដែលបានអនុម័ត ដោយមាត្រា៣៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ បានផ្តល់គុណវុឌ្ឍដ៏ពេញលេញ ដល់គោលការណ៍របស់ខ្លួន ដោយចែងថា "នៅក្នុងមាត្រានេះ គ្មានអ្វីដែលនឹងត្រូវប៉ះពាល់ដល់ការជំនុំជម្រះ និងការផ្តន្ទាទោសនៃជនណាម្នាក់ចំពោះអំពើ

ឬការខកខានណាមួយ នៅពេលដែលអំពើនោះ ត្រូវបានប្រព្រឹត្តមានលក្ខណៈព្រហ្មទណ្ឌ បើយោងទៅតាមគោលការណ៍ទូទៅនៃច្បាប់ ទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិផ្សេងៗ"។

៧២. បើពិចារណាអំពីការជំទាស់ ដោយសំអាងលើគោលការណ៍នៃគ្មានច្បាប់គឺគ្មានទោស ទៅនឹងការអនុវត្តនូវការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះកំពូល (Appeals Chamber) របស់តុលាការ ICTY បានពន្យល់ថា តុលាការត្រូវតែ "ជឿថា ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ដែលជនត្រូវចោទ ត្រូវបានចោទប្រកាន់នោះ គឺ*អាចព្យាករមុន*បានយ៉ាងគ្រប់គ្រាន់ហើយថា ច្បាប់ដែលចែងអំពីការទទួលខុសត្រូវនោះត្រូវតែអាចរកមើលបានយ៉ាងគ្រប់គ្រាន់នៅក្នុងរយៈពេលពាក់ព័ន្ធ ដោយពិចារណាអំពីភាពជាក់លាក់នៃច្បាប់អន្តរជាតិនៅពេលធ្វើការវាយតម្លៃនោះ"។ អង្គជំនុំជម្រះកំពូលនេះបានកត់សម្គាល់ឃើញថា មាត្រា២៦ នៃក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសហព័ន្ធ សង្គមនិយមយ៉ូហ្គូស្លាវី បានកំណត់នូវទម្រង់នៃការទទួលខុសត្រូវស្រដៀងគ្នាដ៏គួរឲ្យចាប់អារម្មណ៍មួយ បើធៀបទៅនឹងការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមហើយមាត្រានេះបានជួយឲ្យមានសញ្ញាណនេះឡើង ។

៧៣. ទោះជាយ៉ាងនេះក្តី អ្វីដែលសំខាន់នោះគឺថា អង្គជំនុំជម្រះកំពូលនេះ ក៏បានសម្រេចថា *បើទោះជាគ្មានបទប្បញ្ញត្តិជាតិក្តី* សេចក្តីសម្រេច និងលិខិតុបករណ៍ផ្លូវច្បាប់ដូចបានកំណត់នៅក្នុងករណី *ព្រះរាជអាជ្ញាតទល់នឹង Tadić ដែល*បង្កើតបានជាគោលការណ៍នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នឹងពិតជាអាចគ្រប់គ្រាន់ តាមសញ្ញាណដ៏សមស្រប។ អង្គជំនុំជម្រះកំពូលនេះបានពន្យល់ថា ច្បាប់ទំនៀមទម្លាប់អាចផ្តល់ជាគោលការណ៍ណែនាំគ្រប់គ្រាន់ និងមាន "លំហូរស្របគ្នា និងលក្ខណៈយូរអង្វែងមួយនៃសេចក្តីសម្រេចចិត្តប្រព័ន្ធតុលាការ លិខិតុបករណ៍អន្តរជាតិ និងច្បាប់ជាតិ [ពីប្រព័ន្ធជាតិខុសៗគ្នា] ដែលនឹងអាចអនុញ្ញាតឲ្យបុគ្គលគ្រប់រូបកំណត់ជាបទបញ្ជា នូវអំពើរបស់ខ្លួនឲ្យស្របទៅតាមហ្នឹង ហើយនឹងអាចផ្តល់ដល់បុគ្គលនោះនូវសញ្ញាណដ៏សមស្រប"។ ហេតុដូច្នេះ ដោយមិនគិតថាតើយុត្តាធិការជាតិ ជាក់លាក់ណាមួយមានច្បាប់ស្តីពីចំនុចនេះ ចរិតលក្ខណៈទំនៀមទម្លាប់នៃគោលការណ៍ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានបញ្ជាក់ថាពិតប្រាកដក្នុងលំហូរនៃសេចក្តីសម្រេច និងលិខិតុបករណ៍ផ្លូវច្បាប់ នឹងមានគ្រប់គ្រាន់ ។

៧៤. ដូច្នេះ *ដោយមិនគិតពី* ខ្លឹមសារនៃច្បាប់កម្ពុជា ការអនុវត្តការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមនឹងមិនបំពានដល់គោលការណ៍*គ្មានច្បាប់គឺគ្មានទោស*ឡើយ។ បន្ថែមលើនេះទៀត នៅប្រទេសកម្ពុជា បើទោះជាមានអ្វីផ្សេងទៀតកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ក៏ដោយ

ក៏ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅតែអាចយកមកប្រើប្រាស់បាន ហើយគិតគូរការទទួលខុសត្រូវទាំងសហចារីកម្ម និង ការសមគំនិត (*Complicité*) ដោយអនុឡោមទៅតាមមាត្រា៨២ និង៨៣ ។

៧៥. ការសមគំនិតត្រូវបានបង្ហាញចេញជាទម្រង់ផ្សេងៗគ្នា អនុឡោមទៅតាមមាត្រា៨៣ដល់៨៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលក្នុងនោះមាន៖ ការញុះញង់ ការឱ្យយោបល់ ការបញ្ជា ការផ្តល់ណែនាំ ការពន្យល់ ការផ្គត់ផ្គង់ជាមធ្យោបាយ ឬការជួយទំនុកបម្រុង ។ តាមពិតការអនុម័តគំរូទោល (Unitary model) ក្រមកម្ពុជាផ្តល់នូវទោសប្បញ្ញត្តិដូចគ្នាដែរសម្រាប់គ្រប់អ្នកចូលរួមក្នុងឧក្រិដ្ឋកម្ម ដោយចែងថា៖ "ជនណាម្នាក់ ដែលចូលរួមដោយចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើសណាមួយ ដោយផ្ទាល់ ឬប្រយោល នឹងត្រូវបានផ្តន្ទាទោសជាមួយការថ្កោលទោស ដូចការផ្តន្ទាទោសចារីដែរដល់ដែរ"។

៧៦. យោងទៅតាមវិធីសាស្ត្របារាំងចំពោះច្បាប់ព្រហ្មទណ្ឌ ច្បាប់កម្ពុជាបានបែកចែកយ៉ាងច្បាស់រវាងទម្រង់ទាំងពីរ៖

(i) សហចារីកម្ម គ្របដណ្តប់នូវ (ក) ឧក្រិដ្ឋកម្មរួម ដែលបានប្រព្រឹត្តដោយគ្មានការព្រមព្រៀងជាមុន (ឧក្រិដ្ឋកម្មហ្វូងមនុស្ស) (ខ) ឧក្រិដ្ឋកម្មផ្អែកទៅលើការព្រមព្រៀងជាមុន (ការរួមដៃប្រព្រឹត្តឧក្រិដ្ឋកម្ម ផែនការ...ជាដើម) និង (គ) ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ក្នុងអំឡុងការព្រមព្រៀងភ្លាមៗ ក្នុងគោលបំណងប្រព្រឹត្តនូវឧក្រិដ្ឋកម្មជាក់លាក់មួយ (ការសមគំនិត) ។

(ii) ការសមគំនិត គ្របដណ្តប់ការញុះញង់ ការបញ្ជា ការផ្គត់ផ្គង់មធ្យោបាយ និងការជួយទំនុកបម្រុង ។

៧៧. អ្នកតាក់តែងសារណានេះមិនសូវជាស្គាល់ច្បាប់យុត្តិសាស្ត្រកម្ពុជា ដែលពាក់ព័ន្ធនឹងការអនុវត្តនូវបទប្បញ្ញត្តិខាងលើក្នុងអំឡុងឆ្នាំរហូតដល់ឆ្នាំ១៩៧៩ ដែរទេ ។ ដោយហេតុថា ប្រព័ន្ធច្បាប់កម្ពុជាពឹងផ្អែកភាគច្រើនទៅលើប្រព័ន្ធព្រហ្មទណ្ឌបារាំងក្តី ការពិនិត្យទៅលើច្បាប់យុត្តិសាស្ត្របារាំងអំពីបញ្ហានេះគឺជាការចាំបាច់។

៧៨. ករណីផ្សេងៗ ដែលបានយកមកជំនុំជម្រះនៅតុលាការបារាំងនឹងអាចសមស្របសងគ្នានឹងទម្រង់ផ្សេងៗរបស់សហកម្មឧក្រិដ្ឋកម្មរួម។ សហចារីកម្ម ហាក់ដូចជាគ្របដណ្តប់យ៉ាងច្បាស់នូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២។ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣នឹងអាចស៊ីគ្នាជាមួយនឹងច្បាប់យុត្តិសាស្ត្របារាំងដោយការអនុវត្តខ្លះៗនូវសញ្ញាណនៃ "ការសមគំនិត" ដូចមានបង្ហាញដោយ ករណីខាងក្រោម៖

សេចក្តីព្រាងសំណុំរឿងក្តីព្រហ្មទណ្ឌលេខ: 001/18-07-2007អ.វ.ត.ក/ក.ស.ច.ស (PTC 02)

(I) <u>*តុលាការ Cour de cassation, Chambre criminelle*</u> ៣១ ធ្នូ ១៩៤៧ ៖ នៅក្នុងករណីនេះ ជនជាប់ចោទត្រូវបានចោទពីបទសមគំនិតក្នុងអំពើចោរកម្ម ដោយបានញុះញង់ឱ្យមានអំពើចោរកម្មនោះកើតឡើង និងរង់ចាំនៅក្នុងឡាន ខណៈដែលបុគ្គលផ្សេងទៀតបានលួចមាស និងគ្រឿងអលង្ការផ្សេងៗទៀតពីស្ត្រីម្នាក់ និងជាមួយនឹងស្ថានទម្ងន់ទោសនៃការបន្លំខ្លួនជាមន្ត្រីប៉ូលីស។ ជនជាប់ចោទមិនបានបន្លំខ្លួនជាមន្ត្រីប៉ូលីសទេ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី គាត់ត្រូវបានផ្តោលទោសពីអំពើចោរកម្មទម្ងន់ទោស។ តុលាការ *Cour de cassation* បានអនុវត្តមាត្រា៥៩ នៃក្រមព្រហ្មទណ្ឌបារាំង ដែលថ្លែងថា ជនសមគំនិតត្រូវទទួលទណ្ឌកម្មដូចគ្នានឹងចារីដែលដល់នៃបទល្មើសនោះដែរ។ តុលាការនេះ បានសម្រេចថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះរាល់ស្ថានទម្ងន់ទោស ដែលបានប្រព្រឹត្តដោយចារីដែលដល់ បើទោះជាខ្លួនមិនបានដឹងអំពីការប្រព្រឹត្តិទាំងនោះក្តី។ វាមានលក្ខណៈគ្រប់គ្រាន់ហើយដែលថា ជនសមគំនិតបានដឹងអំពីអង្គហេតុ ដែលនាំទៅ ឬជំរុញឱ្យមានបទល្មើសនោះឡើង។ វាគឺមិនចាំបាច់ទេដែលថា គាត់គួរដឹងអំពីស្ថានទម្ងន់ទោសនានាដែលនៅអមជាមួយការប្រព្រឹត្តទាំងនោះ ។

(II) <u>*តុលាការ Cour de cassation, Chambre criminelle*</u> ២៨ ឧសភា ១៩៨០ ៖ នៅក្នុងករណីនេះ ជនជាប់ចោទ ដែលជាសមាជិកម្នាក់នៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមួយត្រូវបានផ្តោលទោសពីការសមគំនិតក្នុងការប្រើប្រាស់មូលនិធិក្រុមហ៊ុន (*adus de biens sociaux*) ខុសទិសដៅ ដែលបានប្រព្រឹត្តដោយសហជនជាប់ចោទម្នាក់ទៀត (ប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន)។ ការសមគំនិតរបស់គាត់ត្រូវបានបង្កើតឡើយ ដ្បិតគាត់បានទទួលដឹងឮអំពីការប្រើប្រាស់មូលនិធិខុសទិសដៅ អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកហើយ ដោយឈរលើមូលដ្ឋានការព្រមព្រៀងដោយតុណ្ហីភាព។ យោងទៅតាមតុលាការ *Cour de cassation* ជនជាប់ចោទអនុញ្ញាតឱ្យចារីដែលដល់ប្រព្រឹត្តបទល្មើសហើយអំពើនេះអាចត្រូវបានបញ្ជាក់ថា "វិជ្ជមាន"។ បើទោះជាការសមគំនិតដោយការ-ជួយទំនុកបម្រុងមិនអាចត្រូវបានស្រាវជ្រាវពីកង្វះខាតនៃសកម្មភាពចូលរួម ឬការមិនចូលរួមក៏ដោយ វាមានលក្ខណៈច្បាស់លាស់ ដែលថាដើមចោទជាសមាជិក ម្នាក់នៃក្រុមប្រឹក្សាភិបាល បានដឹងអំពីការប្រើប្រាស់មូលនិធិក្រុមហ៊ុនខុសទិសដៅ ដែល កំពុងត្រូវបានប្រព្រឹត្តដោយប្រធានក្រុមប្រឹក្សាភិបាល និងបានអនុញ្ញាតឱ្យប្រធានរូបនេះ បន្តប្រព្រឹត្តទៀត បើទោះជាគាត់មានមធ្យោបាយផ្លូវច្បាប់ក្នុងការទប់ទល់នឹងអំពើនេះក្តី។

D99/3/24



(III) <u>តុលាការ *Cour de cassation, Chambre criminelle*</u> ១៩ មិថុនា ១៩៨៤ (ក្នុង *Bulletin criminal No. 231*) ៖ នៅក្នុងករណីនេះ សហជនជាប់ចោទចំនួនប្រាំនាក់ត្រូវបានផ្តោលទោសពីអំពើឃាតកម្មលើមនុស្សប្រាំនាក់ ខណៈដែលជនជាប់ចោទពីររូបទៀតត្រូវបានផ្តន្ទាទោសពីការសមគំនិតក្នុងអំពើមនុស្សឃាតនេះ។ ផែនការដើមរបស់សហជនជាប់ចោទទាំងប្រាំពីររូបនេះគឺចាប់ពង្រត់បុរសម្នាក់ឈ្មោះ Messie ក្នុងគោលបំណងសួរចម្លើយគាត់ ហើយអាចនឹងសម្លាប់គាត់ផង និងដើម្បីយកឯកសារព្រមព្រៀងមួយចំនួន។ នៅពេលសហជនជាប់ចោទទាំងប្រាំនាក់ ធ្វើដំណើរទៅកាន់ផ្ទះបុរសនេះ ហើយបុរសរូបនេះមិនបាននៅផ្ទះក៏ដោយ តែបើទោះជាយ៉ាងនេះក្តី ពួកគេបានសម្លាប់សាក្សីប្រាំនាក់ផ្សេងទៀត ដែលនៅក្នុងផ្ទះនោះ។ អ្នកដាក់បណ្តឹង ដែលដើរតួនាទីក្នុងការរៀបចំផែនការ និងផ្តល់ការណែនាំ ប៉ុន្តែមិនបានចូលរួមក្នុងការសម្លាប់នេះទេ ហើយបានចោទប្រកាន់ពីការបំពានមាត្រា៦០ នៃក្រមព្រហ្មទណ្ឌ (ស្តីពីការសមគំនិត)។ គាត់បានផ្តល់ទឡ្ហីករណ៍ថារូបគាត់មិនត្រូវបានផ្តោលទោសពីបទសមគំនិតក្នុងអំពើ ដែលមិនអាចព្យាករទុកជាមុននៅក្នុងអំឡុងពេលនៃការរៀបចំផែនការប្រព្រឹត្តបទល្មើសឡើយ។ តុលាការ *Cour de cassation* បានសម្រេចថា កម្មវត្ថុនីមួយៗនៃអំពើមនុស្សឃាតទាំងប្រាំគឺរួមមានទាំងការរៀបចំ ការសម្របសម្រួល និងការប្រព្រឹត្តអំពើចោរកម្ម ដែលត្រូវបានបញ្ជាដោយដើមចោទ ឬក៏ដើម្បីជួយឲ្យមានការគេចខ្លួន ឬធានានិទណ្ឌភាពរបស់ពួកចារី និងជនសមគំនិត។ តុលាការនេះបានអះអាងជាថ្មីម្តងទៀតអំពីគោលការណ៍ដែលថា ជនសមគំនិតត្រូវទទួលខុសត្រូវចំពោះរាល់ស្ថានទម្ងន់ទោស បើទោះជាខ្លួនមិនបានដឹងអំពីស្ថានទម្ងន់ទោសទាំងនេះក្តី។ តុលាការនេះក៏បានសម្រេចថា ក្នុងករណីនេះ គឺមានទំនាក់ទំនង (*la relation*) រវាងការណែនាំ ដែលផ្តល់ដោយដើមចោទ និងអំពើឃាតកម្មលើមនុស្សប្រាំនាក់នោះ គឺតម្រូវដោយមាត្រា៦០ នៃក្រមព្រហ្មទណ្ឌ ។

៧៩. ហេតុដូច្នេះ សក្តានុពលចំពោះការទទួលខុសត្រូវក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមគឺ (១) អាចព្យាករមុនដោយសមស្រប បើទោះជាគ្មានវត្តមាននៃច្បាប់ជាតិ និងច្បាប់យុត្តិសាស្ត្របារាំង ដែលពាក់ព័ន្ធក៏ដោយ និង (២) លើសពីនេះទៀត ការទទួលខុសត្រូវក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមអាចព្យាករទុកមុន ដ្បិតច្បាប់ជាតិ និងករណីតុលាការបារាំង ដែលពាក់ព័ន្ធនឹងការបកស្រាយច្បាប់កម្ពុជា និងដែលយកគំរូតាមច្បាប់បារាំង បានថែងអំពីការ

ទទួលខុសត្រូវក្រោមទ្រឹស្ដីជាតិ ពាក់ព័ន្ធនឹងគោលការណ៍ទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ទម្រង់ទី១ និងទី៣។

៨០. ជាអវសាន គួរបញ្ជាក់ផងដែរថា ដោយផ្អែកទៅលើច្បាប់យុត្តិសាស្ត្រកម្ពុជា សហកម្មឧក្រិដ្ឋ-កម្មរួមអាចត្រូវបានអនុវត្ត បើទោះជាត្រូវបានហៅឈ្មោះផ្សេងក៏ដោយ គឺដូចជាអ្វីៗ ដែលជាប់ពាក់ព័ន្ធ នឹងច្បាប់បារាំង ដែលជាភាសាខ្មែរថា *ការសមគំនិត*។ អ្វីដែលសំខាន់នោះគឺថា ទស្សនាទាននេះអាចត្រូវបានអនុវត្ត ដោយយោងទៅតាមច្បាប់អន្តរជាតិ បើទោះជាវាមានឈ្មោះអ្វីក៏ដោយ ។

**ខ. កង្វល់អំពីការទទួលខុសត្រូវទទួលខុសត្រូវធំទូលាយជ្រុលត្រូវបានការកាត់បន្ថយ នៅកម្រិតអន្តរជាតិ និងដោយការយកចិត្តទុកដាក់អំពីផលប្រយោជន៍សំខាន់ៗ**

៨១. អ្នកផ្ដល់មតិខ្លះបានបង្ហាញពីភាល់អំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលអាចដឹងមុននៅក្រៅគោលបំណងរួមក្រោមសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ហើយខ្លាចថាទម្រង់នៃការទទួលខុសត្រូវ នេះអាចបំពានលើគោលការណ៍នៃពិរុទ្ធភាព (*nullum crimen sine culpa*)។ ការព្រួយបារម្ភនោះគឺថា ពិរុទ្ធភាពនៃជនល្មើសទី២ ដែលបានចូលរួមក្នុងការរៀបចំផែនការឧក្រិដ្ឋកម្ម ឬការព្រមព្រៀង ហើយបានដឹងជាមុនអំពីបទល្មើសនៅក្រៅផែនការនោះ គឺមិនសមាមាត្រនឹងពិរុទ្ធភាព នៃជនល្មើសទី១ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយបានព្រមព្រៀងគ្នាបន្ថែមលើបទល្មើសមួយទៀតទេ។ នៅក្នុងទ្រឹស្ដីបែបនេះ មានការតវ៉ាថា ជនល្មើសទី២អាចត្រូវបានគេរកឃើញថា មានពិរុទ្ធពីបទមនុស្សឃាត បើទោះជាគ្មានចេតនាសម្លាប់ក៏ដោយ ដែលផ្ទុយទៅវិញត្រូវបានលាក់បំពួន និងការពារដោយជនល្មើសទី១ ដែលបានប្រព្រឹត្តបទមនុស្សឃាតដោយផ្ទាល់។

៨២. ខាងក្រោមនេះគឺជាការឆ្លើយតបទៅនឹងការជំទាស់ទាំងអស់នេះ ៖

(i) ពាក់ព័ន្ធនឹងកម្រិតនៃពិរុទ្ធភាព បើទោះជាជនល្មើសទី២គ្មានចេតនា (*dolus directus*) ប្រព្រឹត្តបទឧក្រិដ្ឋ ដែលមិនបានរួបរួមព្រមព្រៀងក៏ដោយ ក៏គាត់នៅតែជាភាគី នៅក្នុងសហកម្មឧក្រិដ្ឋកម្ម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលបានព្រមពៀង ហើយឧក្រិដ្ឋកម្មបន្ថែមទៀត អាចនឹងកើតឡើងផងដែរ គឺទាំងក្នុងការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្ម និងការដែលគាត់ខកខានមិនបានដកខ្លួន ឬបញ្ឈប់ឧក្រិដ្ឋកម្មនោះ ខណៈដែលខ្លួនព្យាករដឹងមុនពីឧក្រិដ្ឋកម្មបន្ថែមនេះ។ ដូច្នេះ មានទំនាក់ទំនងសាមញ្ញមួយរវាងឧក្រិដ្ឋកម្មដែល

បានព្រមព្រៀង ដែលជាការប្រព្រឹត្តិ និងជាឥរិយាបទផ្នែកសតិបញ្ញារបស់ជនល្មើសទី២ និងឧក្រិដ្ឋកម្មបន្ថែម ដែលបានប្រព្រឹត្តផ្ទាល់ដោយជនល្មើសទី១។

ជាធម្មតា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១បង្កើតនូវវេទិកា ដែលចារីដែលអាចប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣។ ពិសេស នៅពេលជនម្នាក់ត្រូវប្រឈមមុខនឹងរដ្ឋាភិបាល/ភាពជាប់ចោទពីបទឧក្រិដ្ឋ ដែលទទួលទណ្ឌកម្មជាផ្លូវការនៅកម្រិតសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ហើយការគាំទ្រជាផ្លូវការចំពោះឧក្រិដ្ឋ-កម្មដំបូងៗនេះអាច "បើកទ្វារ" ទៅរកប្រភេទបន្ទាប់ទៀតនៃឧក្រិដ្ឋកម្ម។ ការឃុំឃាំង ឬការនិរទេសខុសច្បាប់ ដែលបានដាក់ទណ្ឌកម្មជាផ្លូវការ អាចនាំទៅរកការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀត។ ហានិភ័យនេះត្រូវបានបន្ថែមទៀត នៅពេលដែលជនម្នាក់ត្រូវប្រឈមមុខនឹងសហកម្មឧក្រិដ្ឋកម្មរួមច្រើនទម្រង់ ដែលពាក់ព័ន្ធ នឹងមនុស្សជាច្រើនជាមួយនឹងគោលបំណងរួមទូលំទូលាយមួយ និងអនុវត្តគោលបំណងរួមនោះ ដោយប្រើ-ប្រាស់ស្ថាប័នស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម (ជួនកាលប្រើប្រាស់ចារីដែលល់តែម្តង)។

ដោយហេតុថាឧក្រិដ្ឋកម្ម ដែលយើងកំពុងដោះស្រាយនេះ ត្រូវបានប្រព្រឹត្តក្នុងទ្រង់ទ្រាយមួយធំ ហើយត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលយូរមកហើយនោះ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី៣ជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និត ហើយជាញឹកញាប់ សហ-កម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ប្រែក្លាយទៅជាសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១តាមរយៈ "សញ្ញាណ"។ ក្នុងស្ថានភាពបោសសំអាតជាតិពន្ធុ គោលបំណងរួមដើមអាចជាការនិរ-ទេស។ ក្នុងអំឡុងនៃការនិរទេស ការសម្លាប់ ការរំលោភផ្លូវភេទ ការបំផ្លិចបំផ្លាញត្រូវបានប្រើប្រាស់ជាប្រចាំ ដើម្បីសម្រេចគោលបំណងនេះ។ ដំបូងឡើង ឧក្រិដ្ឋកម្មទាំងនេះអាចជាផលវិបាកដែលអាចព្យាករមុនក្នុងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣របស់គោលបំណងរួមនៃការនិរទេស។ ដូចសមាជិកសហកម្មឧក្រិដ្ឋកម្មរួមដឹងអំពីឧក្រិដ្ឋកម្មបន្ថែមទាំងនេះ និងបន្តសម្រេចគោលបំណងរួមនេះ ហើយនេះអាចបង្កើតបានជាចេតនារួមនៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ ក្នុងការប្រព្រឹត្ត(អតីតសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣)ឧក្រិដ្ឋកម្មទាំងនេះ ។

និយាយជាទូទៅ ត្រូវតែមានយន្តការទទួលខុសត្រូវ និងធ្វើឱ្យរាងចាលមួយ ដើម្បីដោះស្រាយជាមួយនឹងជន ដែលដឹងមុនពីឧក្រិដ្ឋកម្មបន្ថែម ប៉ុន្តែនៅតែបន្តរួមចំណែកក្នុង

សហកម្មឧក្រិដ្ឋកម្ម និងខកខានមិនបង្ការ ឬបញ្ឈប់ឧក្រិដ្ឋកម្មបន្ថែមនោះ ឬដកខ្លួនចេញពីសហកម្មឧក្រិដ្ឋកម្មនោះ ដើម្បីជៀសវាងមិនឲ្យក្លាយទៅជាអ្នកចូលរួមក្នុងឧក្រិដ្ឋកម្មបន្ថែមនេះ ។

(ii) បន្ថែមលើនេះទៀត ពិរុទ្ធភាព និងភាពគួរឲ្យស្តីបន្ទោសតិចតួចជាងហ្នឹងទៀតរបស់ជនល្មើសទី២ (ដោយសន្មតថាមានរឿងដូចនេះមែន) អាចឲ្យទទួលខុសត្រូវក្នុងការផ្តន្ទាទោស និងតាមពិត ក្នុងករណីសហកម្មឧក្រិដ្ឋកម្មរួមមួយចំនួន ដែលបានវិភាគក្នុងផ្នែកមុនៗ ការផ្តន្ទាទោសត្រូវបានបន្ថយចំពោះជន ដែលមានតួនាទី ឬពិរុទ្ធភាពតិចតួចជាងចំពោះបទល្មើសដូចគ្នា។

(iii) ចំណែកឯមូលដ្ឋាន និងហេតុផលរបស់សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ វាមានកត់សម្គាល់ថា ទម្រង់នៃការទទួលខុសត្រូវនេះត្រូវបានបង្កើតឡើង ដោយពិចារណាអំពីគោលនយោបាយសាធារណៈ ពោលគឺភាពចាំបាច់ក្នុងការការពារសង្គមប្រឆាំងនឹងជន ដែលប្រមូលគ្នាជាក្រុម ដើម្បីចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មនានា និងជនដែលរឹងរូសក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម បើទោះជាពួកគេព្យាករថា មានឧក្រិដ្ឋកម្មធ្ងន់ធ្ងរបន្ថែមទៀត ក្រៅពីការប្រព្រឹត្តិសហកម្មរួមហ្នឹងក៏ដោយ។ ការពិចារណាទៅលើគោលនយោបាយទាំងនេះត្រូវបានចែងយ៉ាងច្បាស់ ដោយតុលាការកំពូលសហរដ្ឋអាមេរិក ក្នុងករណី *Tison* តទល់នឹង *Arizona* ក្នុងឆ្នាំ១៩៨៧ និងដោយសមាជិកនៃតុលាការ (House of Lords) ក្នុងឆ្នាំ១៩៩៧ ក្នុងករណី *Regina* តទល់នឹង *Powell* និង *Daniels* និងក្នុងករណី *Regina* តទល់នឹង *Powell* (*Anthony*) ក្នុងបរិបទនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅថ្នាក់ជាតិ ។

៨៣. ជាអវសាន្ត ការព្រួយបារម្ភពីការបំពានក្នុងការអនុវត្តការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមគឺត្រូវបានបន្ធូរបន្ថយនៅកម្រិតអន្តរជាតិពីព្រោះ (i) ការជំនុំជម្រះកម្រិតអន្តរជាតិត្រូវបានរំពឹងថាមានការគោរពពេញលេញចំពោះសិទ្ធិរបស់ជនជាប់ចោទ។ នេះគួរសបញ្ជាក់ឲ្យឃើញថាចុងចោទអាចនាំយកនូវធាតុផ្សំផ្សេងៗមកបង្ហាញថា ខ្លួនមិនអាចព្យាករពីឧក្រិដ្ឋកម្មបន្ថែម (ដូច្នេះហើយខ្លួននឹងមិនត្រូវមានពិរុទ្ធដោយសារឧក្រិដ្ឋកម្មនេះ)បានឡើយ។ (២) នៅក្នុងតុលាការកូនកាត់ និងតុលាការអន្តរជាតិ ចៅក្រមអាជីព ដែលមានសមត្ថភាពអនុវត្តការយកចិត្តទុកដាក់ និងឆន្ទានុសិទ្ធិ ជាអ្នកកំណត់ថាតើ ពិរុទ្ធភាពរបស់ជនល្មើសមានភស្តុតាងគ្រប់គ្រាន់ ហួសពីវិមតិសង្ស័យ។ លើសពីនេះទៅទៀត វាត្រូវតែបញ្ជាក់ម្តងទៀតថា ភាពជាក់លាក់នៃឧក្រិដ្ឋកម្ម

អន្តរជាតិគឺពាក់ព័ន្ធនឹងចរិកលក្ខណៈរួមរបស់ឧក្រិដ្ឋកម្មទាំងនោះ និងអង្គហេតុដែលថា ឧក្រិដ្ឋកម្មទាំងនេះកើតឡើង នៅពេលមនុស្សចូលរួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋជាទ្រង់ទ្រាយធំ ។

៨៤. សញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួមបង្ហាញឱ្យឃើញថា មានសារប្រយោជន៍ចំពោះយុត្តិធម៌ព្រហ្មទណ្ឌ ប្រសិនបើសញ្ញាណនេះត្រូវបានប្រើប្រាស់ជាមួយនឹងឆន្ទានុសិទ្ធិ និងការគោរពពេញលេញ នូវគោលការណ៍ជាសារវន្តុ នៃការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានបង្ហាញដោយករណីឧក្រិដ្ឋកម្មសង្គ្រាមថ្មីៗមួយ ដែលបាននាំមកជំនុំជម្រះនៅតុលាការយោធាចក្រភពអង់គ្លេស មានទីតាំងនៅក្រុង Colchester ពោលគឺករណី R. V. Evans និង *អ្នកដទៃទៀត* (៣ វិច្ឆិកា ២០០៥)។ ករណីនេះកើតចេញពីលទ្ធផល នៃឧប្បត្តិហេតុនានាក្នុងប្រទេសអ៊ីរ៉ាក់កើតឡើងក្នុងឆ្នាំ២០០៣។ ចុងចោទប្រាំពីរនាក់ ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត និងបណ្តាលឱ្យមានភាពអសណ្តាប់ធ្នាប់ហឹង្សា អំឡុងពេលប្រតិបត្តិការឈប់ឆែកឆេរ ដែលក្នុងនោះពួកគេបានវាយប្រហារជនស៊ីវិលអ៊ីរ៉ាក់មួយចំនួន និងបានសម្លាប់ជនជាតិអ៊ីរ៉ាក់ម្នាក់។ ព្រះរាជអាជ្ញាមិនអាចចង្អុលបានថា ចុងចោទណាមួយជាជនដែលសម្លាប់ជនរងគ្រោះនោះទេ ប៉ុន្តែបានផ្តល់ទឡ្ហីករណ៍ថា ទាហានទាំងនោះបានចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមមួយ ក្នុងការប្រព្រឹត្តិអំពើមនុស្សឃាតនោះ។ ចៅក្រមបានអះអាងថា “ប្រសិនបើមានទាហានតែម្នាក់ ឬច្រើននាក់បានប្រើប្រាស់កម្លាំងសមស្រប ពីដំបូងដែ ដើម្បីធ្វើការឆែកឆេរស្របច្បាប់ ប៉ុន្តែក្រោយមកបានប្រើប្រាស់កម្លាំងនេះខុសចំនួន ដែលក្លាយជាកម្លាំងខុសច្បាប់ នៅពេលនោះ សមាជិកក្រុមយាមល្បាត ដែល ដែលបំពេញតួនាទីស្របច្បាប់ ដូចជា [...] ការយាមល្បាត និងការការពារតំបន់នោះ ក៏អាចក្លាយជាអ្នកមានទោសកំហុសដែរ ប្រសិនជាមានភស្តុតាងបង្ហាញថា ពួកគេបានចូលរួម ឬពាក់ព័ន្ធនឹងការប្រើកម្លាំងខុសច្បាប់ ហើយនៅពេលនោះ ពួកគេក៏បានប្រមើលឃើញថា អំពើរបស់ទាហាន និងកម្លាំងខុសច្បាប់ទាំងនោះអាចបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ ឬនាំឱ្យមានការបាត់បង់ជីវិតជនស៊ីវិល”។ ទោះជាយ៉ាងនេះក្តី ដោយគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ឱ្យក្រុមប្រឹក្សាភិបាលនៃតុលាការយោធានេះធ្វើការវិនិច្ឆ័យទោស ចៅក្រមបានសម្រេចឱ្យក្រុមប្រឹក្សាភិបាលមិនផ្តន្ទាទោសចុងចោទទាំងនោះទេ។ ហេតុដូច្នេះ ចៅក្រម ទោះជាទូទៅលើកកម្ពស់ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ដោយផ្អែកលើភាពដែលអាចព្យាករមុន ក៏ដោយ ក៏បានរកឃើញថា កង្វះខាតនៃភស្តុតាងបណ្តាលឱ្យទ្រឹស្តីនេះមិនអាចយកទៅអនុវត្តបាន ។

## សេចក្ដីសន្និដ្ឋាន

៨៥. ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មានច្បាប់ទំនៀមក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានចែងអំពីការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ខុសៗគ្នាបី។ ច្បាប់ទាំងនេះអាចអនុវត្តបានចំពោះប្រទេសកម្ពុជា។ ទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួមអាចត្រូវបានអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីឲ្យសមស្របនឹងគោលការណ៍គ្មានច្បាប់គឺគ្មានទោស និងគួរត្រូវបានអនុវត្តនៅពេលណាដែលសមស្រប ដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនូវភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងដើម្បីធានានូវភាពស្របគ្នា នៃការប្រើប្រាស់ទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

| | | | |
|---|---|---|---|
| ២៧ តុលា ២០០៨ | សាស្ត្រាចារ្យ Antonio Cassese សម្រាប់ជាសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី | Florence អ៊ីតាលី | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |